**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត**
**និង វិទ្យាសាស្រ្តសេដ្ឋកិច្ច**

# សារណាបញ្ចប់ការសិក្សា

# ដំណើរការជួញដូរមូលបត្រលើ ទីផ្សារមូលបត្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៨


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **លឹម វិតា**

សាស្រ្តាចារ្យណែនាំ
លោក **សួន ចំរើន**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១១


ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ដំណើរការជួញដូរមូលបត្រលើ ទីផ្សារមូលបត្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **លឹម វិតា**

សាស្ត្រាចារ្យណែនាំ
លោក **សួន ចំរើន**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១១

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ លឹម វិភា ជានិស្សិតបរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី ៤ ក្រុម $B_4B_1$ ជំនាន់ទី ១១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានធ្វើរបាយការណ៍សារណាបញ្ចប់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា"។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់៖

លោកឪពុក អ្នកម្តាយ និងក្រុមគ្រួសារដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ និងខិតខំផ្គត់ផ្គង់ទាំងសម្ភារៈសិក្សា ប្រាក់ឧបត្ថម្ភក្នុងការចាយវាយប្រចាំថ្ងៃ ព្រមទាំងកម្លាំងចិត្តដែលជួយជ្រោមជ្រែងអធ្យាស្រ័យយោគយល់ និងការទុកពេលវេលាឲ្យនាងខ្ញុំគ្រប់គ្រាន់ក្នុងការមកសិក្សា និងសសេរសម្រេចអត្ថបទស្រាវជ្រាវសារណាមួយនេះ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចគ្រប់រូប ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់ជាឯកសារ ចំណេះដឹង គំនិតយោបល់ ដំបូន្មានក៏ដូចជាការតម្រង់ទិសក្នុងការសិក្សា និងអាជីពការងារ ដើម្បីជាស្ពាននាំនាងខ្ញុំទៅកាន់ភាពជោគជ័យនាពេលអនាគត។

សាស្រ្តាចារ្យ សួន ចំរើន ដែលជាសាស្ត្រាចារ្យណែនាំ ក្នុងការសសេររបាយការណ៍សារណាបញ្ចប់ការសិក្សានេះ។ ទោះជាលោកគ្រូមានកាលវិភាគមមាញឹកយ៉ាងណា ក៏លោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ពន្យល់ណែនាំ ចង្អុលបង្ហាញឲ្យធ្វើការកែប្រែនូវចំណុចខ្វះខាតមួយចំនួនដែលមាននៅក្នុងអត្ថបទ។ លោកគ្រូបានយោគយល់ និងព្យាយាមសម្របសម្រួលច្រើនដើម្បីផ្តល់ភាពងាយស្រួលដល់នាងខ្ញុំក្នុងការសាកសួរយោបល់។

រៀមច្បងដែលបានបន្សល់ទុក ស្នាដៃល្អជាច្រើន សម្រាប់ទុកជាគំរូ និងព័ត៌មានដ៏មានតម្លៃដល់នាងខ្ញុំផ្ទាល់ ក៏ដូចជាប្អូនៗនិស្សិតជំនាន់ក្រោយដែលមានចំណាប់អារម្មណ៍លើប្រធានបទនេះ។

មិត្តរួមថ្នាក់ទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្ត និងទំនុកចិត្តដល់រូបនាងខ្ញុំក្នុងការសសេរបញ្ចប់អត្ថបទស្រាវជ្រាវនេះ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះអ្នកមានគុណគ្រប់រូប ឲ្យជួបប្រទះតែសេចក្តីសុខសុភមង្គល វិបុលសុខនិងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

វិស័យមូលបត្រនៅប្រទេសកម្ពុជា ទើបតែបង្កើតឡើងក្នុងឆ្នាំ ២០១២ ដែលវិស័យនេះត្រូវបានគេចាត់ទុកជាវិស័យមួយដែលមានវ័យក្មេងជាងគេ ក្នុងចំណោមវិស័យដទៃទៀត។ ស្របពេលដែលកំនើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកលូតលាស់ខ្លាំងក្នុងកំឡុងឆ្នាំចុងក្រោយនេះ ការកកើតឡើងនៃវិស័យមូលបត្រគឺជាឱកាសមួយសម្រាប់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសធ្វើការបោះទុនដើម្បីប្រាក់ចំណេញ។ បើទោះជាយ៉ាងណាក្តី ការវិនិយោគពីសំណាក់អ្នកវិនិយោគក្រៅប្រទេសតែម្ខាង គឺមិនគ្រប់គ្រាន់ក្នុងការជំរុញឲ្យមានដំណើរការទៅមុខជាសន្ទុះនោះទេ។ ដូច្នេះហើយ យើងត្រូវមានវិធានការក្នុងការជំរុញឲ្យមានការចូលរួមពីវិនិយោគិនក្នុងស្រុក និងប្រជាពលរដ្ឋទូទៅឲ្យបានកាន់តែច្រើន។ ប៉ុន្តែការចូលរួមនេះនឹងអាចធ្វើទៅបាន លុះត្រាតែប្រជាពលរដ្ឋនិងវិនិយោគិនទូទៅមានចំណេះដឹងពាក់ព័ន្ធនឹងវិស័យមូលបត្រនៅកម្ពុជា។ បច្ចុប្បន្ន ប្រជាជនកម្ពុជាភាគច្រើន ពុំទាន់យល់ច្បាស់ពីអ្វីជាទីផ្សារមូលបត្រ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ដំណើរការប្រតិបត្តិការនៃទីផ្សារមូលបត្រ និងនីតិវិធីក្នុងការជួញដូរមូលបត្រនៅឡើយទេ។

ដោយមើលឃើញពីចំណុចនេះហើយ ទើបនាងខ្ញុំសម្រេចធ្វើការសិក្សាលើវិស័យមូលបត្រសម្រាប់របាយការណ៍សារណាបញ្ចប់ការសិក្សាជាមួយនឹងប្រធានបទ "ដំណើរការជួញដូរមូលបត្រលើទីផ្សារបន្ទាប់កម្ពុជា"។ នៅក្នុងអត្ថបទស្រាវជ្រាវនេះ នាងខ្ញុំនឹងធ្វើការសិក្សាផ្តោតសំខាន់ទៅលើនីតិវិធីនៃការជួញដូរមូលបត្រ ជំហានដំបូងមុននឹងធ្វើការជួញដូរ ដំណើរការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រកម្ពុជា និងយន្តការផាត់ទាត់និងទូទាត់មូលបត្រ បន្ទាប់ពីត្រូវបានធ្វើការបន្សីរួចនៅដំណាក់កាលជួញដូរ។ នាងខ្ញុំសង្ឃឹមថា ការស្រាវជ្រាវនេះនឹងអាចក្លាយជា ឯកសារចងក្រងខ្លីៗ និងងាយស្រួលយល់សម្រាប់វិនិយោគិនគ្រប់រូប ដែលមានបំណងចង់សាកល្បងធ្វើការវិនិយោគលើទីផ្សារមូលបត្រ។

ការខិតខំព្យាយាមឥតខ្ចោះយ៉ាងណាក៏គង់មានចន្លោះប្រហោងអាចនឹងកើតមានឡើង ហេតុដូចនេះហើយនាងខ្ញុំសង្ឃឹមថា លោក លោកស្រី សាស្ត្រាចារ្យ គណៈកម្មការវាយតម្លៃ មេត្តាខន្តីអភ័យទោសដល់រាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនាទៅលើពាក្យពេចន៍ និងអក្ខរាវិរុទ្ធ ដែលយើងខ្ញុំបង្កឡើងដោយអនុគ្រោះ។ អាស្រ័យដូចនេះ នាងខ្ញុំរីករាយនឹងរង់ចាំជានិច្ចនូវរាល់ការរិះគន់ដើម្បីស្ថាបនា និងព្យាយាមកែលម្អឲ្យកាន់តែប្រសើរឡើងមួយកម្រិតទៀត។

# មាតិកា


បញ្ជីអក្សរកាត់ ..... v
បញ្ជីតារាង ..... vi
បញ្ជីរូបភាព ..... vii
បញ្ជីឧបសម្ព័ន្ធ ..... viii


# សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
២. ចំណោទបញ្ហា ..... ២
៣. គោលបំណងនៃការស្រាវជ្រាវ ..... ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៤
៦.១ ការប្រមូលទិន្នន័យ ..... ៤
៦.១.១. ទិន្នន័យចម្បង ..... ៤
៦.១.២ ទិន្នន័យបន្ទាប់បន្សំ ..... ៤
៦.២ ការវិភាគទិន្នន័យ ..... ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៥


# ជំពូកទី១

# រំលឹកទ្រឹស្តី


១.១ ទីផ្សារមូលបត្រ ..... ៦
១.១.១ និយមន័យ ..... ៦
១.១.២ ប្រវត្តិទីផ្សារមូលបត្រ ..... ៦
១.២ ប្រភេទនៃទីផ្សារមូលបត្រ ..... ៧
១.២.១ ទីផ្សារដំបូង (Primary Market) ..... ៧
១.២.២ ទីផ្សារបន្ទាប់ (Secondary Market) ..... ៨
១.៣ ប្រភេទនៃមូលបត្រ ..... ៩
១.៣.១ មូលបត្រកម្មសិទ្ធិ ..... ៩

១.៣.២ មូលបត្របំណុល.......................................................................... ៩
១.៣.៣ ឧបករណ៍និស្សន្ទ .......................................................................១០
១.៤ គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រ...........................................១១
១.៤.១ គុណសម្បត្តិនៃទីផ្សារមូលបត្រ.........................................................១១
១.៤.២ គុណវិបត្តិនៃទីផ្សារមូលបត្រ...........................................................១៣
១.៥. អ្នកចូលរួមក្នុងទីផ្សារមូលបត្រ...............................................................១៤
១.៥.១ តួអង្គលើទីផ្សារដំបូង .....................................................................១៤
១.៥.១.១ ក្រុមហ៊ុនធានាទិញមូលបត្រ ..........................................................១៤
១.៥.១.២ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ.....................................................១៥
១.៥.១.៣ វិនិយោគិន ..................................................................................១៦
១.៥.២ តួអង្គលើទីផ្សារបន្ទាប់.......................................................................១៦
១.៥.២.១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា.........................................................១៦
ក. ប្រតិបត្តិករទីផ្សារមូលបត្រ ...........................................................១៦
ខ. ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ .............................១៧
គ. ប្រតិបត្តិកររក្សាទុកមូលបត្រ.........................................................១៧
១.៥.២.២ វិនិយោគិន ..................................................................................១៧
១.៥.២.៣ ក្រុមហ៊ុនមូលបត្រ.........................................................................១៨
១.៥.២.៤ អន្តរការីទីផ្សារ .............................................................................១៨
១.៥.៣ តួអង្គចូលរួមដទៃផ្សេងទៀត.............................................................. ២០
១.៥.៣.១ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ............................. ២០
១.៥.៣.២ ភ្នាក់ងារបញ្ជិការមូលបត្រ ........................................................... ២០
១.៥.៣.៣ ភ្នាក់ងាចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ............................. ២១
១.៥.៣.៤ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់លើវិស័យមូលបត្រ ........................... ២១
១.៥.៣.៥ ក្រុមហ៊ុនផ្តល់សេវាបកប្រែផ្នែកមូលបត្រ ......................................... ២២
១.៥.៣.៦ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម.......................................................... ២២
១.៥.៣.៧ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ..........................................................២៣

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

២.១ គោលដៅ និងគោលបំណងរបស់គ.ម.ក. ..... ២៤
២.២ ចក្ខុវិស័យ និងបេសកកម្មរបស់គ.ម.ក ..... ២៤
២.២.១ ចក្ខុវិស័យ ..... ២៥
២.២.២ បេសកកម្ម ..... ២៥
២.៣ ប្រធាន និងសមាជិករបស់គ.ម.ក. ..... ២៥
២.៤ ទីតាំងរបស់គ.ម.ក ..... ២៦
២.៥ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញាបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៦
២.៥.១ រូបសញ្ញា ..... ២៦
២.៥.២ អត្ថន័យនៃរូបសញ្ញា ..... ២៧
២.៥.៣ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៧
២.៥ រចនាសម្ព័ន្ធអង្គការចាត់តាំងគ.ម.ក ..... ២៨

## ជំពូកទី ៣

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១ ចក្ខុវិស័យ និងបេសកកម្ម ..... ២៩
៣.១.១ ចក្ខុវិស័យ ..... ២៩
៣.១.២ បេសកកម្ម ..... ២៩
៣.២ ប្រវត្តិនៃផ្សារមូលបត្រកម្ពុជា ..... ៣០
៣.៣ រចនាសម្ព័ន្ធនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ..... ៣១

## ជំពូកទី ៤

## ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា

៤.១ ការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា ..... ៣៤
៤.១.១ នីតិវិធីនៃការជួញដូរមូលបត្រ ..... ៣៤
៤.១.១.១ ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ..... ៣៤
៤.១.១.២ ការបើកគណនីជួញដូរ ..... ៣៤
៤.១.១.៣ ការដាក់បញ្ជាជួញដូរ ..... ៣៥

៤.១.២ ដំណើរការប្រតិបត្តិការទីផ្សារ....................................................................................................៣៦
៤.១.២.១ ពេលវេលានៃការជួញដូរ ..........................................................................................៣៦
៤.១.២.២ ឯកតាបញ្ជា ឯកតាគម្លាតថ្លៃ ........................................................................................ ៣៧
៤.១.២.៣ ដែនកំណត់នៃការប្រែប្រួលថ្លៃមូលបត្រ ........................................................................៣៨
៤.១.២.៤ គោលការណ៍ដេញថ្លៃ ................................................................................................៣៨
៤.១.២.៥ ថ្លៃពិសេស .............................................................................................................៤០
៤.២ ដំណើរការការជួញដូរមូលបត្រលើទីផ្សារបន្ទាប់ ......................................................................................៤១
៤.២.១ ដំណើរការនៃការអនុវត្តការជួញដូរមូលបត្រ ........................................................................................៤១
៤.២.២ យន្តការនៃការផាត់ទាត់ និងទូទាត់....................................................................................................៤៣
៤.២.២.១ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់.................................................៤៤
៤.២.២.២ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ .....................................................៤៥
៤.២.២.៣ ដំណើរការផាត់ទាត់ ..................................................................................................៤៦
៤.២.២.៤ ដំណើរការទូទាត់......................................................................................................៤៧
៤.២.២.៥ កម្រៃសេវាផាត់ទាត់និងទូទាត់ ....................................................................................៥០
៤.២.៣ យន្តការនៃការរក្សាទុកមូលបត្រ ........................................................................................................៥០
៤.៣ ទិន្នន័យសំខាន់ៗទាក់ទងនឹងការជួញដូរមូលបត្រនៅកម្ពុជា.....................................................................៥១
៤.៤ ចំណុចខ្លាំង និងចំណុចខ្សោយនៃការជួញដូរមូលបត្រនៅកម្ពុជា.................................................................៥៦
៤.៤.១ ចំណុចខ្លាំង ......................................................................................................................................៥៦
៤.៤.២ ចំណុចខ្សោយ ...................................................................................................................................៥៧

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

សេចក្ដីសន្និដ្ឋាន ...................................................................................................................................................៥៨
អនុសាសន៍..........................................................................................................................................................៥៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម.ក. : គណៈកម្មការមូលបត្រកម្ពុជា

ផ.ម.ក. : ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

CSA : (Cash Settlement Agent) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

SF : (Securities Firm) ក្រុមហ៊ុនមូលបត្រ

CSO : (Cash Settlement Operator) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

CSX : Cambodia Security Exchange ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

SECC : Security Exchange Committee in Cambodia គណៈកម្មការមូលបត្រកម្ពុជា

NBC : National Bank of Cambodia ធនាគារជាតិនៃកម្ពុជា

CSD : Cash Settlement Depository ប្រតិបត្តិកររក្សាទុកមូលបត្រ

CMA : Client Money Account គណនីទូទាត់សាច់ប្រាក់អតិថិជន

OTC : Over the Counter Market

# បញ្ជីតារាង

តារាងទី ៤.១: ឯកតាគម្លាតថ្លៃ ........................................................................................ ៣៧
តារាងទី ៤.២: គោលការណ៍ដេញថ្លៃ..................................................................................... ៣៨
តារាងទី ៤.៣: ការដាក់បញ្ជាព្រមពេលគ្នា............................................................................ ៣៩
តារាងទី ៤.៤: ការបែងចែកបរិមាណមូលបត្រ....................................................................... ៤០
តារាងទី ៤.៥: ថ្លៃពិសេស ............................................................................................... ៤០
តារាងទី ៤.៦: វិនិយោគិនបរទេសសំខាន់ៗទាំង ៦ក្នុងផ្សារមូលបត្រកម្ពុជា ............................. ៥៦

# បញ្ជីរូបភាព

រូបភាពទី ២.១: រូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ........................................ ២៦
រូបភាពទី ២.២: ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ........................................ ២៧
រូបភាពទី ២.៣: រចនាសម្ព័ន្ធនៃគណៈកម្មការមូលបត្រកម្ពុជា ........................................ ២៨
រូបភាពទី ៣.១: រចនាសម្ព័ន្ធនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................ ៣២
រូបភាពទី ៣.២: ក្រុមប្រឹក្សានៃផ្សារមូលបត្រកម្ពុជា ........................................ ៣៣
រូបភាពទី ៤.១: ពេលវេលាជួញដូរនៅផ្សារមូលបត្រកម្ពុជា ........................................ ៣៧
រូបភាពទី ៤.២: នីតិវិធីនៃការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា ........................................ ៤២
រូបភាពទី ៤.៣: ការជួញដូរមូលបត្រសរុបរបស់វិនិយោគិនក្នុងស្រុក និងបរទេស ........................................ ៥២
រូបភាពទី ៤.៤: ការជួញដូរមូលបត្រសរុបនៃនីតិបុគ្គល និងរូបវន្តបុគ្គល ........................................ ៥៣
រូបភាពទី ៤.៥: បរិមាណនិងតម្លៃនៃការជួញដូរមូលបត្រសរុបប្រចាំថ្ងៃគិតជាមធ្យម ........................................ ៥៤
រូបភាពទី ៤.៦: ចំនួនគណនីជួញដូរមូលបត្រ ........................................ ៥៥

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : វិសោធនកម្មលើកទី៣ នៃវិធានប្រតិបត្តិការទីផ្សារ
ឧបសម្ព័ន្ធទី២ : វិសោធនកម្មលើកទី៧ នៃវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់
ឧបសម្ព័ន្ធទី៣ : វិសោធនកម្មលើកទី៦ នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
ឧបសម្ព័ន្ធទី៤ : គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ
ឧបសម្ព័ន្ធទី៥ : គោលការណ៍ណែនាំស្តីពីយន្តការនៃការទទួលបញ្ជាជួញដូរមូលបត្រ
ឧបសម្ព័ន្ធទី៦ : គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន
ឧបសម្ព័ន្ធទី៧ : Overview of Cambodia Securities Market

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ស្របនឹងកំណើនសេដ្ឋកិច្ចនៅអត្រា ៧% ក្នុងកំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ [1] ប្រទេសកម្ពុជាបាននឹងកំពុងឈានជំហានទៅមុខជាលំដាប់។ ការស្ទុះឡើងនៃសេដ្ឋកិច្ចនេះ បានបង្កើតជាបរិយាកាសមួយដ៏ល្អ ដែលអាចទាក់ទាញបានទាំងវិនិយោគិនក្នុងស្រុក និងក្រៅស្រុកឲ្យមកធ្វើការបណ្តាក់ទុនយ៉ាងសស្រាក់សស្រាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយមានការផ្តួចផ្តើមពីរដ្ឋាភិបាលកម្ពុជា លើគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ យើងសង្កេតឃើញថាទីផ្សារមូលបត្របាននឹងកំពុងរីកលូតលាស់យ៉ាងខ្លាំងក្នុងសេដ្ឋកិច្ចកម្ពុជា ពីព្រោះប្រទេសកម្ពុជាអាចចាត់ទុកជាទីផ្សារមួយដ៏វ័យក្មេងក្នុងវិស័យនេះ ដែលជាហេតុធ្វើឲ្យវិនិយោគិនយល់ថាមានឱកាសទទួលបានផលចំណេញច្រើន។

ជាមួយគ្នានេះផងដែរ ដើម្បីធានាដល់ភាពរលូននៃដំណើរការរបស់ទីផ្សារមូលបត្រកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ត្រូវបានបង្កើតឡើង និងដើរតួយ៉ាងសំខាន់ក្នុងការតាក់តែងច្បាប់ស្តីពីការប្រព្រឹត្តទៅនូវទីផ្សារមូលបត្រ លក្ខខណ្ឌក្នុងការចូលរួម នីតិវិធីក្នុងការជួញដូរមូលបត្រ ធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានដល់សាធារណជនតាមរយៈបណ្តាញសង្គម និងលើគេហទំព័ររបស់ខ្លួន។ ក្រោយមក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ត្រូវបានបង្កើតឡើងដើម្បីធ្វើជាប្រតិបត្តិករនៃផ្សារមូលបត្រកម្ពុជា។ តាមរយៈការធ្វើសន្និសិទ្ធ សិក្ខាសិលា កម្មវិធីប្រកួតប្រជែងទាក់ទងនឹងមូលបត្រ យើងឃើញថា វិស័យនេះទទួលបានការចាប់អារម្មណ៍ច្រើនពីសាធារណជន និងក្រុមហ៊ុនឯកជនជាច្រើន។ ម្យ៉ាងវិញទៀតការទាក់ទាញនេះ បានធ្វើឲ្យមហាជនចង់ដឹងចង់លឺពីដំណើរការ និងនីតិវិធីក្នុងការជួញដូរមូលបត្រ ក្នុងទីផ្សាភាគហ៊ុនកម្ពុជា។ នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តកម្ពុជាបានឡើងទីផ្សារដោយជោគជ័យមុនគេ។ ការប្រព្រឹត្តដូចនេះបានជម្រុញឲ្យមានការចូលរួមពីក្រុមហ៊ុនឯកជនមួយចំនួនជាបន្តបន្ទាប់ និងការត្រៀមខ្លួនរបស់ក្រុមហ៊ុនមួយចំនួនទៀត ដើម្បីឡើងទីផ្សារមូលបត្រ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រត្រូវបានចាត់ទុកជាកាតាលីករមួយរបស់សេដ្ឋកិច្ច ព្រោះវាជាមធ្យោបាយមួយក្នុងការកៀងគរមូលធនសម្រាប់ផ្តល់ជាហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ។ អាស្រ័យ

[1] https://tradingeconomics.com/cambodia/gdp.

ហេតុនេះហើយ ការរីកលូតលាស់នៃវិស័យមូលបត្រគឺជាកត្តាចាំបាច់ដែលត្រូវតែយកចិត្តទុកដាក់ដើម្បីពង្រឹងនូវការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងស្រុក និងតាមតំបន់អាស៊ី។ ដោយឡែកនៅប្រទេសកម្ពុជា បើទោះបីជាមានការជ្រោមជ្រែងពីរាជរដ្ឋាភិបាល ក្នុងការពង្រីកនូវវិស័យមូលបត្រក៏ពិតមែន យើងសង្កេតឃើញថាធនធានមនុស្សក្នុងវិស័យនេះនៅមានកម្រិត ស្ថាប័នពាក់ព័ន្ធនៅខ្វះបច្ចេក-វិទ្យាក្នុងការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព ព្រោះ វិស័យមូលបត្រទើបតែបង្កើតឡើងឲ្យដំណើរការ ដូចនេះហើយវិស័យនេះនៅមានភាពវ័យក្មេង ហើយការរីកលូតលាស់មិនទាន់ទូលំទូលាយនៅឡើយទេ។ មួយវិញទៀត ប្រជាជនកម្ពុជាភាគច្រើនពុំទាន់បានយល់ឲ្យស៊ីជម្រៅអំពីដំណើរការនៃការជួញដូរមូលបត្រនៅលើទីផ្សារនៅឡើយទេ។ ដោយមើលឃើញនូវចំណុចខ្វះខាតទាំងនេះហើយ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ ដំណើរការទិញ លក់មូលបត្រនៅទីផ្សារមូលបត្រកម្ពុជា ដើម្បីស្រាយបំភ្លឺនូវចម្ងល់របស់វិនិយោគិនដែលមានចំណាប់អារម្មណ៍ចង់វិនិយោគក្នុងវិស័យនេះ។ ដើម្បីសម្រេចនូវគោលបំណងនៃការស្រាវជ្រាវនេះ របាយការណ៍ស្រាវជ្រាវនេះនឹងឆ្លើយនូវសំណួរខាងក្រោមនេះ៖

តើការទិញ លក់មូលបត្រនៅលើទីផ្សារមូលបត្រនៅកម្ពុជាដំណើរការទៅយ៉ាងដូចម្តេច?

- តើកត្តាអ្វីខ្លះដែលវិនិយោគិនត្រូវពិចារណាមុនធ្វើការវិនិយោគ?
- តើលក្ខខណ្ឌអ្វីខ្លះដែលវិនិយោគិនត្រូវបំពេញមុននឹងធ្វើការវិនិយោគ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់លើដំណើរការជួញដូរមូលបត្រនៅកម្ពុជា ក្រុមហ៊ុនចូលរួមក្នុងវិស័យមូលបត្រនេះ និងតួអង្គសំខាន់ផ្សេងទៀត។ គោលបំណងនៃការស្រាវជ្រាវនេះអាចសង្ខេបជាចំណុចដូចខាងក្រោម៖

- ស្វែងយល់ពីដំណើរការនៃការជួញដូរមូលបត្រកម្ពុជា
- ស្វែងយល់ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ស្វែងយល់ពីគណៈកម្មការមូលបត្រកម្ពុជា
- ស្វែងយល់ពីកត្តាចាំបាច់មុននឹងធ្វើការវិនិយោគលើវិស័យមូលបត្រ
- ស្វែងយល់ពីនីតិវិធី និងលក្ខខណ្ឌចាំបាច់ក្នុងការជួញដូរមូលបត្រក្នុងផ្សារមូលបត្រកម្ពុជា។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយហេតុថា ទីផ្សារមូលបត្រទើបតែបើកសម្ពោធឲ្យដំណើរការជាផ្លូវការ នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១១ នោះការលូតលាស់នៃផ្សារមូលបត្រមិនទាន់បានទូលំទូលាយនៅឡើយ។ ដូច

នេះហើយ ការស្រាវជ្រាវនេះនឹងធ្វើការសិក្សាទៅលើ ការជួញដូរមូលបត្រក្នុងផ្សារមូលបត្រកម្ពុជា (ទីផ្សារបន្ទាប់) ដោយផ្តោតសំខាន់ពីឆ្នាំ ២០១២ ដល់ ២០១៨ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជារួមមក ការស្រាវជ្រាវនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចរៀបរាប់ខាងក្រោមនេះៈ

ចំពោះនាងខ្ញុំ

- ផ្តល់ជាចំណេះដឹងឲ្យកាន់តែស៊ីជម្រៅទៅលើវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានរៀនកន្លងមក។
- ពង្រឹងនូវសមត្ថភាពក្នុងការស្រាវជ្រាវ ប្រមូលឯកសារ ទិន្នន័យធ្វើជាភស្តុតាងក្នុងការតាក់តែងអត្ថបទនេះឡើង។
- ចេះវិភាគ និងរៀបចំឯកសារឲ្យមានសណ្តាប់ធ្នាប់ និងមានទំនួលខុសត្រូវចំពោះការងាររបស់ខ្លួន។

ចំពោះនិស្សិត និងអ្នកស្រាវជ្រាវ

- ជាទុនមួយសម្រាប់និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ដែលមានចំណាប់អារម្មណ៍លើប្រធានបទនេះ ឲ្យស្វែងយល់បន្ថែម។
- រំលឹកឡើងវិញនូវទ្រឹស្តីដែលបានយល់ដឹងកន្លងមក។
- ស្គាល់នូវពាក្យបច្ចេកទេសថ្មីៗទាក់ទងនឹងវិស័យនេះ ដែលពុំធ្លាប់បានយល់ពីមុនមក។

ចំពោះមជ្ឈដ្ឋានទូទៅ

- ដើរតួជាព័ត៌មាន និងឯកសារដល់សាធារណជនដែលបានបំណងចង់ដឹងលឺ ពីការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា
- ផ្តល់ជាឯកសារដល់ក្រុមហ៊ុនដែលត្រៀមខ្លួនឡើងទីផ្សារ និងវិនិយោគិនឲ្យយល់ដឹងពីដំណើរការទិញ លក់មូលបត្រលើទីផ្សារមូលបត្រកម្ពុជា។
- ចំពោះក្រុមហ៊ុនមូលបត្រកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា
- របាយការណ៍នៃការស្រាវជ្រាវនេះ អាចជាផ្តល់គំនិតដល់ស្ថាប័ន ដើម្បីធ្វើឲ្យប្រសើរឡើងនូវចំណុចខ្វះខាតមួយចំនួន ដែលជាបញ្ហាចោទទៅលើការប្រព្រឹត្តទៅនៃប្រតិបត្តិការរបស់ទីផ្សារសព្វថ្ងៃ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីប្រមូលយកទិន្នន័យ និងព័ត៌មានសម្រាប់របាយការណ៍ស្រាវជ្រាវនេះ នាងខ្ញុំបានផ្អែកលើទិន្នន័យ ២ យ៉ាងដូចខាងក្រោម៖

### ៦.១ ការប្រមូលទិន្នន័យ

#### ៦.១.១ ទិន្នន័យចម្បង

- ការណែនាំ និងចង្អុលបង្ហាញដោយយកទុកចិត្តពីសាស្ត្រាចារ្យណែនាំ
- ការពន្យល់បកស្រាយ និងការណែនាំយ៉ាងល្អិតល្អន់ពីអ្នកជំនាញរបស់ក្រុមហ៊ុនផ្សារមូល-បត្រកម្ពុជា

#### ៦.១.២ ទិន្នន័យបន្ទាប់បន្សំ

- ទិន្នន័យទទួលបានពីប្រព័ន្ធអ៊ីនធើណេត
- ព័ត៌មានទទួលបានពីគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនមូលបត្រកម្ពុជាផ្សេងទៀត
- និក្ខេបបទ របាយការណ៍កម្មសិក្សា ឬ សារណាបញ្ចប់ការសិក្សារបស់សិស្សច្បងដែលពាក់ព័ន្ធនឹងប្រធានបទ។

### ៦.២ ការវិភាគទិន្នន័យ

ទិន្នន័យទាក់ទងនឹងផ្សារមូលបត្រកម្ពុជា គឺនឹងត្រូវបានធ្វើការវិភាគតាមបែបពិពណ៌នាដោយផ្អែកលើតួលេខដែលបានដាក់បង្ហាញ និងធ្វើការប្រៀបធៀបទិន្នន័យទាំងនោះពីឆ្នាំមួយទៅឆ្នាំមួយទៀតដើម្បីឃើញពីភាពខុសគ្នានៃការឡើងចុះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាជំនួយដល់អ្នកអានក្នុងការងាយស្រួលយល់នូវអត្ថន័យ និងគំនិតសំខាន់របស់របាយការណ៍ស្រាវជ្រាវនេះ ការសិក្សានេះនឹងត្រូវបានបែងចែកជា ៤ ជំពូកធំៗ៖

- សេចក្តីផ្តើម
- ជំពូក ១ រំលឹកទ្រឹស្តី
- ជំពូក ២ គណៈកម្មការមូលបត្រកម្ពុជា
- ជំពូក ៣ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ជំពូក ៤ ដំណើរការទិញលក់មូលបត្រកម្ពុជា
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# រចនាសម្ព័ន្ធនៃរបាយការណ៍ស្រាវជ្រាវ



# ជំពូកទី ១
# រំលឹកត្រីស្ដី

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១ ទីផ្សារមូលបត្រ

### ១.១.១ និយមន័យ

ទីផ្សារមូលបត្រគឺជាពាក្យបន្សំមកពីពាក្យ ទីផ្សារ និងមូលបត្រ។ ទីផ្សារបានដល់ទីកន្លែងដែលអ្នកលក់ និងអ្នកទិញជួបគ្នាដើម្បីធ្វើការដោះដូរទំនិញ ឬសេវាកម្មក្នុងតម្លៃកំណត់មួយ។ រីឯមូលបត្រសំដៅដល់គំរូប័ណ្ណ ដែលអាចធ្វើការដោះដូរ ជាសាធារណៈ ឬ លើទីផ្សារមូលបត្រ។

ទីផ្សារមូលបត្រ ត្រូវបានគេទទួលស្គាល់ថាជា កន្លែងសម្រាប់ធ្វើការជួញដូរលក់មូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ យោងតាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន "ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្វីការទិញ លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម"[2]។

### ១.១.២ ប្រវត្តិនៃទីផ្សារមូលបត្រ

ទីផ្សារភាគហ៊ុន បានកកើតឡើងតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុនត្រូវបានចាប់ផ្តើមនៅពេលបណ្តាប្រទេសនៅទ្វីបអាមេរិច (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតដែលមានដូចជាប្រទេសហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុប មានបំណងចាប់ផ្តើមអាជីវកម្មទំហំធំដែលទាមទារឱ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់ មានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំ បានតែម្នាក់ឯងនោះទេ។ ដើម្បីធ្វើការវិនិយោគ វិនិយោគិន បានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទុនរួម។ ក្រុមហ៊ុនរួមទុន ដែលមានដើមកំណើតនៅប្រទេសហូឡង់បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្ម ដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុន ឌឺ ឌាចហ៍ អ៊ីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ឧបករណ៍ដែលអាចជួញដូរបាននេះអនុញ្ញាតឱ្យភាគហ៊ុនិក មានភាពងាយស្រួលទិញ-លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួន ជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ

[2] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *គណៈកម្មការមូលបត្រកម្ពុជាគឺជាអ្វី?*

និងវិនិយោគិនដទៃទៀត។ គំនិតនោះទទួលបានជោគជ័យដោយសារការលក់ភាគហ៊ុន បានរីករាលដាល ដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀត ដូចជា ប្រទេសព័រទុយហ្គាល់ អេស្បាញ និងបារាំង។ នៅទីបំផុត ការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។

ឧស្សាហាកម្មដទៃទៀត ក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហាកម្ម បានចាប់ផ្តើមប្រើការលក់ភាគហ៊ុនជាវិធីដើម្បីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនូវមូលធននេះ បានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហាកម្មទំនើប។ ការកើនឡើង នូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឱ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផល ពាណិជ្ជករភាគហ៊ុន បានសម្រេចចិត្តទៅជួបគ្នានៅហាងកាហ្វេ មួយនៅទីក្រុងឡុងដ៍។ ក្រោយមក ហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។ ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Ex-change) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុង ភីឡាឌែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០[3]៕

## ១.២ ប្រភេទនៃទីផ្សារមូលបត្រ

### ១.២.១ ទីផ្សារដំបូង ( Primary Market)

ទីផ្សារដំបូង គឺជាទីផ្សារដែលធ្វើការជួញដូរ ឬទិញលក់មូលបត្រ ដែលទើបនឹងបោះផ្សាយលក់ជាលើកដំបូង។ គេអាចហៅទីផ្សារនេះបានម្យ៉ាងទៀតថាជាទីផ្សារបោះផ្សាយមូលបត្រ។ ទីផ្សារនេះទទួលបានប្រភពមូលធនសំខាន់ពីប្រាក់សន្សំរបស់សាធារណៈជន ក៏ដូចជាអង្គការមិនមែនស្ថា-ប័នហិរញ្ញវត្ថុមួយចំនួនទៀតដែរ។ ទីផ្សារដំបូងអនុវត្តនូវមុខងារសំខាន់បំផុតរបស់ទីផ្សារមូលធននោះ គឺជាមុខងារសេដ្ឋកិច្ច មានន័យថាយកមូលធនពីអ្នកមានមូលធនលើស ទៅផ្តល់ឲ្យអ្នកមានតម្រូវការមូលធន ឬជាការគៀគរមូលធនដែលទំនេរយកទៅវិនិយោគបន្ថែម។ ជារួមមក ទីផ្សារដំបូងគឺជាកន្លែងទិញ លក់បណ្តាមូលបត្រដែលទើបនឹងបោះផ្សាយលើកដំបូងរវាងអ្នកបោះផ្សាយ (អ្នកលក់) និងអ្នកវិនិយោគ (អ្នកទិញ)។

តួនាទីចម្បងរបស់ទីផ្សារដំបូង គឺបង្កើតទំនិញឲ្យទីផ្សារជួញដូរ និងធ្វើឲ្យកើនមូលធនវិនិ-យោគដល់វិស័យសេដ្ឋកិច្ច។ តួនាទីនោះគឺ៖

- ដំណើរការនៃមូលបត្រ ដើម្បីប្រមូលនូវមូលធនពេលត្រូវការ។

[3] គណៈកម្មការមូលបត្រកម្ពុជា (២០១៧), *"ព្រឹត្តិបត្តិមូលបត្រ" ចេញផ្សាយលេខ ២ ខែមករា ឆ្នាំ ២០១៧*

- ដំណើរការហិរញ្ញវត្ថុដោយផ្ទាល់ ដែលផ្ទេរប្រាក់ទៅជាទម្រង់មូលធនរយៈពេលមធ្យម និងរយៈពេលវែង។

**១.២.២ ទីផ្សារបន្ទាប់** (Secondary Market)

ទីផ្សារបន្ទាប់ គឺជាទីផ្សារដែលធ្វើការជួញដូរមូលបត្រទាំងឡាយ ដែលធ្លាប់បានធ្វើការជួញដូរម្តងរួចមកហើយ នៅក្នុងទីផ្សារដំបូង។ ទីផ្សារនេះជាចំណែកមួយដ៏សំខាន់នៃទីផ្សារមូលបត្រដោយភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទីផ្សារដំបូង។

ទីផ្សារបន្ទាប់អនុវត្តនូវបណ្តាមុខងារដូចខាងក្រោម៖

- បង្កើតលក្ខណៈងាយស្រួលដើម្បីលក់ឧបករណ៍ហិរញ្ញវត្ថុ ក្នុងគោលបំណងប្រមូលនូវសាច់ប្រាក់ និងបង្កើននូវឧបករណ៍ហិរញ្ញវត្ថុ។ មានន័យថា បង្កើននូវលក្ខណៈងាយស្រួលក្នុងការផ្ទេរសាច់ប្រាក់ ទៅជាឧបករណ៍ហិរញ្ញវត្ថុ និង ផ្ទេរពីឧបករណ៍ហិរញ្ញវត្ថុទៅជាសាច់ប្រាក់ (សន្ទនីយភាពសាច់ប្រាក់)។
- រកផលចំណេញពីការកាន់កាប់នូវមូលបត្រ (ទទួលបានភាគលាភ ឬការប្រាក់)។
- កំណត់តម្លៃមូលបត្រឲ្យបានសមស្រប នៅលើមូលដ្ឋានដេញថ្លៃដោយសេរី (ការប្រកួតប្រជែងដោយសេរី)។

នៅលើទីផ្សារបន្ទាប់ គេប្រើប្រាស់ប្រតិបត្តិការតាម ២ វិធី[4]៖

- Organized Exchanged Market: ប្រតិបត្តិការតាមមូលដ្ឋានជួញដូរ គឺជាមជ្ឈដ្ឋានជួញដូរមានទីតាំងត្រឹមត្រូវ មានវិធាន និងបទបញ្ញត្តិសម្រាប់គ្រប់គ្រងឲ្យត្រឹមត្រូវ។
- Over the Counter Market (OTC): តាមរយៈការទិញ លក់មូលបត្រដែលធ្វើការជួញដូរមូលបត្រនៅទីកន្លែងផ្សេងគ្នា និងក្នុងតម្លៃព្រមព្រៀងគ្នា។ ទីផ្សារនេះមិនមានវិធាន និងបទបញ្ញត្តិគ្រប់គ្រងដូច Organized Exchanged Market ទេ[5]។

[4] ឆេង សុភក្រ្តា និងឆេង ដាលីន, *"ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា"*, (និក្ខេបបទបរិញ្ញាបត្រ,សាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២, ១៣)

[5] សួន ចំរើន (២០០៩), *ធនាគារ និងហិរញ្ញវត្ថុ, ទំព័រទី ៣៩-៤០*

## ១.៣ ប្រភេទនៃមូលបត្រ

### ១.៣.១ មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិគឺជា មូលបត្រមួយប្រភេទដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនចុះបញ្ជីដើម្បីកៀរគរមូលធន ដែលនៅសល់ពីសាធារណៈជន ទុកវិនិយោគបន្ថែមលើអាជីវកម្មរបស់ខ្លួន។ អ្នកទិញមូលបត្រប្រភេទនេះ នឹងក្លាយជាភាគទុនិកមួយចំណែករបស់ក្រុមហ៊ុនដែលបោះផ្សាយលក់ និងទទួលបានប្រាក់ចំណេញតាមរយៈការចែកភាគលាភ។ អ្នកកាន់កាប់នេះក៏មានសិទ្ធិចូលរួមបោះឆ្នោត និងធ្វើការត្រួតពិនិត្យទៅលើការសម្រេចចិត្តណាមួយរបស់ក្រុមហ៊ុនផងដែរ។ ប៉ុន្តែអ្នកកាន់កាប់មូលបត្រនេះក៏ចូលរួមក្នុងភាពជោគជ័យ និងបរាជ័យរបស់ក្រុមហ៊ុនបោះផ្សាយដែរ ពោលគឺភាគលាភត្រូវបានបែងចែកតាមប្រាក់ចំណេញរបស់ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយនោះ។ មូលបត្រកម្មសិទ្ធិចែកចេញជា ២ ប្រភេទ៖

- ភាគហ៊ុនធម្មតា (Common Stock)៖ ផ្តល់ឲ្យភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោត និងត្រួតពិនិត្យលើការសម្រេចចិត្តមួយចំនួន។ ម្ចាស់ភាគហ៊ុនអាចទទួលបានភាគលាភទៅតាមការកើនឡើងឬថយចុះនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ អ្នកកាន់កាប់ភាគហ៊ុនប្រភេទនេះទទួលបានសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនធ្វើការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។
- ភាគហ៊ុនបុរិមា (Preferred Stock)៖ ពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ ប៉ុន្តែអាចទទួលបានភាគលាភចែកមុនម្ចាស់ភាគហ៊ុនធម្មតា នៅពេលដែលក្រុមហ៊ុនជួបប្រទះនូវភាពក្ស័យធន។

### ១.៣.២ មូលបត្របំណុល

មូលបត្របំណុលអាចត្រូវបានគេហៅថា ប័ណ្ណបំណុល វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ ឬ ផលបត្រពាណិជ្ជកម្មអាស្រ័យលើអាយុកាល ឬ ថេរវេលាផ្សេងទៀត។ អ្នកកាន់មូលបត្របំណុលជាទូទៅមានសិទ្ធិទទួលបានការទូទាត់មូលធន និងការប្រាក់ក្នុងចំនួនមួយដែលបានកំណត់ក្នុងលក្ខខណ្ឌនៃកិច្ចសន្យា។ ចំនួនទឹកប្រាក់ទូទាត់មានលក្ខណៈថេរ។ មូលបត្របំណុល ត្រូវបានចេញផ្សាយសម្រាប់ការិយបរិច្ឆេទថេរ និងអាចទូទាត់បាននៅចុងបញ្ចប់នៃការិយបរិច្ឆេទនោះ។ អ្នកកាន់កាប់មូលបត្របំណុលទទួលបានអាទិភាពក្នុងការទទួលបានប្រាក់សំណងពីក្រុមហ៊ុនក្នុងករណីក្រុមហ៊ុននោះក្ស័យធន។

### ១.៣.៣ ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរវេទីវគឺជាឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យារវាងភាគីពីរ ឬច្រើនដែលតម្លៃរបស់វាត្រូវបានកំណត់ដោយការប្រែប្រួលនៃទ្រព្យសកម្ម។ ទ្រព្យសកម្មទាំងនោះជាទូទៅរួមមាន ភាគហ៊ុន សញ្ញាបណ្ណ វត្ថុធាតុ (មាស ប្រេង) រូបិយប័ណ្ណ អត្រាការប្រាក់និងសន្ទស្សន៍ទីផ្សារ។

ទម្រង់ទូទៅនៃឧបករណ៍និស្សន្ទរួមមាន[6]៖

**កិច្ចសន្យានាពេលអនាគត (Future Contract)** គឺជាទម្រង់នៃឧបករណ៍និស្សន្ទមួយប្រភេទដែលជាកិច្ចព្រមព្រៀងរវាងភាគីពីរដែលយល់ព្រមក្នុងការលក់ទ្រព្យសកម្មមួយតាមតម្លៃ ដែលបានកំណត់ និងព្រមព្រៀងគ្នា។ ជាទូទៅគេនឹងប្រើកិច្ចសន្យាអនាគតដើម្បីទប់ស្កាត់ហានិភ័យក្នុងកំឡុងពេលជាក់លាក់ណាមួយ។

**កិច្ចសន្យាបន្ត (Forward Contract)** គឺជាប្រភេទឧបករណ៍និស្សន្ទមួយ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យានាពេលអនាគត។ ភាពខុសគ្នាសំខាន់នោះគឺ កិច្ចសន្យាបន្តមិនអាចជួញដូរបាននៅ Organized Exchanged Market អាចជួញដូរនៅលើ Over the Counter Market (OTC ) តែប៉ុណ្ណោះ។

**កិច្ចសន្យាដោះដូរ (Swap Contract)** គឺជាប្រភេទឧបករណ៍និស្សន្ទមួយទៀត ដែលជាកិច្ចសន្យាមួយរវាងភាគីទាំងពីរដែលយល់ស្របនឹងលក្ខខណ្ឌប្រាក់កម្ចី។ ឧបករណ៍និស្សន្ទប្រភេទនេះអនុញ្ញាតឲ្យភាគីទាំងពីរធ្វើការផ្លាស់ប្តូរពី កម្ចីអត្រាការប្រាក់ប្រែប្រួលទៅជាប្រាក់កម្ចីអត្រាការប្រាក់ថេរ ឬ ពីថេរមកប្រែប្រួលវិញ។

**កិច្ចសន្យាជម្រើស (Option Contract)** គឺស្រដៀងគ្នាទៅនឹងកិច្ចសន្យានាពេលអនាគត ដែលវាជាកិច្ចព្រមព្រៀងរវាងភាគីទាំងពីរដែលផ្តល់ឱកាសឲ្យទិញ ឬ លក់ឧបករណ៍ហិរញ្ញវត្ថុនោះនៅកាលបរិច្ឆេទអនាគតដែលបានកំណត់ទុកជាមុន។ ភាពខុសគ្នាសំខាន់រវាងកិច្ចសន្យាជម្រើស និងកិច្ចសន្យាអនាគតគឺថា ជាមួយនឹងកិច្ចសន្យាជម្រើស អ្នកទិញមិនមានកាតព្វកិច្ចធ្វើប្រតិបត្តិការទិញឬលក់ទេ ប្រសិនបើគាត់សម្រេចចិត្តមិនធ្វើដូច្នេះ។ កិច្ចសន្យាជម្រើសអាចត្រូវបានប្រើដើម្បីចៀសវាងនឹងការធ្លាក់ចុះនៃតម្លៃ និងដើម្បីផ្តល់ឱ្យអ្នកទិញនូវឱកាសសម្រាប់ទទួលបានហិរញ្ញវត្ថុតាមរយៈការរំពឹងទុក។

[6] https://www.investopedia.com/terms/d/derivative.asp

## ១.៤ គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រ

### ១.៤.១ គុណសម្បត្តិនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ជាចលករយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រោះគេអាចចាត់ទុកវាជាឧបករណ៍វាស់ស្ទង់ស្ថានភាពសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់ភាពប្រែប្រួលក្នុងបរិបទសេដ្ឋកិច្ចជាតិ និងអន្តរជាតិនឹងធ្វើឲ្យមានផលប៉ះពាល់ខ្លាំងដល់ស្ថានភាពទីផ្សារមូលបត្រភ្លាម។ ឥទ្ធិពលនេះអាចឆ្លុះបញ្ចាំងបានតាមរយៈសន្ទស្សន៍នៃភាគហ៊ុន ឬការឡើងចុះនៃភាគហ៊ុនរបស់ក្រុមហ៊ុនមូលបត្រនីមួយៗ ដែលធ្វើឲ្យមានការប្រែប្រួលទំនុកចិត្តរបស់វិនិយោគិនគ្រប់រូប។ ហេតុនេះហើយ យើងអាចនិយាយបានថា ទីផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់បណ្ដាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់[7]។

ជាសង្ខេប ទីផ្សារមូលបត្រផ្ដល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច និងវិនិយោគិនដូចតទៅ៖

**ចំពោះសេដ្ឋកិច្ចជាតិ**

(១) ទីផ្សារមូលបត្រជួយជំរុញឲ្យមហាជនបង្កើននូវប្រាក់សន្សំ និងកៀរគរមូលធនដែលមិនមានតម្រូវការនិងនៅសេសសល់ យកទៅប្រើប្រាស់ក្នុងការវិនិយោគនានា។

(២) ទីផ្សារមូលបត្រជាមធ្យោបាយមួយសម្រាប់អាជីវកម្មខ្នាតតូចក្ដី ធំក្ដីក្នុងការប្រមូលយកមូលធនដែលនៅសេសសល់យកមកទ្រទ្រង់ និងពង្រីកអាជីវកម្មរបស់ខ្លួន។

(៣) ទីផ្សារមូលបត្រគឺជាទីផ្សារឧបករណ៍ហិរញ្ញវត្ថុ ដែលជួយសម្រួលដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តនូវគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការបោះផ្សាយមូលបត្រនិងទាក់ទាញនូវវិនិយោគិនទាំងឡាយ។

(៤) ទីផ្សារមូលបត្រជាមធ្យោបាយមួយដែលអាចទាញយកមូលធនមិនត្រឹមតែក្នុងប្រទេសប៉ុន្តែពីមូលធនបរទេសទៀតផង។

(៥) ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានដំណើរការ និងចរាចរយ៉ាងរស់រវើកលើទីផ្សារ។

(៦) ទីផ្សារមូលបត្រជាកាតាលីករជួយជំរុញឲ្យបណ្ដាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយមានប្រសិទ្ធភាព និមានតម្លាភាព។

(៧) ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់សន្សំ និងវិនិយោគ។

[7] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រកម្ពុជា*

(៨) ទីផ្សារមូលបត្រជាជំហានចម្បងសម្រាប់ប្រទេសកំពុងអភិវឌ្ឍឆក់ឱកាសដើម្បីពង្រីកសេដ្ឋកិច្ចរបស់ខ្លួន។

**ចំពោះវិនិយោគិន**

*(១) ឱកាសវិនិយោគ និងប្រាក់ចំណេញ*

ជំនួសឱ្យ ឬ បន្ថែមលើការបើកអាជីវកម្មដោយខ្លួនឯង ការកាន់កាប់ភាគហ៊ុនផ្តល់ឱ្យវិនិយោគិន នូវឱកាសក្នុងការចូលរួមចំណែកក្នុងអាជីវកម្មមួយដែលមិនតម្រូវឱ្យមានជំនាញនិងបទពិសោធន៍ពាក់ព័ន្ធ ឬការតាមដានត្រួតពិនិត្យជាប់ជាប្រចាំឡើយ។ ទន្ទឹមនឹងនេះ ប្រាក់ចំណេញពីការជួញដូរ និងភាគលាភទទួលបានពីការកាន់កាប់ភាគហ៊ុន អាចមានចំនួនច្រើនលើសផលវិនិ-យោគដទៃទៀត។

*(២) លទ្ធភាពក្នុងការវិនិយោគដោយវិនិយោគិនតូចៗ*

ទីផ្សារភាគហ៊ុនអនុញ្ញាតឱ្យវិនិយោគិនដែលមានប្រាក់តិចតួច អាចក្លាយជាម្ចាស់(មួយផ្នែក) នៃក្រុមហ៊ុនធំៗ និងទទួលបានផលចំណេញដូចវិនិយោគិនជាអ្នកមាននិងជាស្ថាប័នផងដែរ ទៅតាមសមមាត្រភាគហ៊ុនដែលពួកគេកាន់កាប់។

*(៣) ការលើកទឹកចិត្តផ្នែកពន្ធ*

- មិនមានពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិពេលជួញដូរភាគហ៊ុន
- មិនមានពន្ធលើចំណេញមូលធន(capital gain)
- មិនមានពន្ធលើភាគលាភសម្រាប់និវេសនជនកម្ពុជា ចំណែកអនិវេសនជន ពន្ធលើភាគលាភត្រូវបន្ថយមកត្រឹម៧% (ពីអត្រាដើម ១៤%)

*(៤) ពិពិធកម្មនៃសំណុំវិនិយោគ និងចំណូលបន្ថែម*

ក្រៅពីប្រភពចំណូលចម្បងដូចជាប្រាក់ខែ ឬ ប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀត ក្នុងទម្រង់ជាការប្រាក់ ដែលបានពីការដាក់ប្រាក់សន្សំមានកាលកំណត់ ចំណូលពីការជួល ឬ ចំណេញពីអចលនទ្រព្យ លោកអ្នកអាចវិនិយោគក្នុងផ្សារភាគហ៊ុនដើម្បីធ្វើពិពិធកម្មសំណុំវិនិយោគ ដើម្បីទទួលបានចំណូលបន្ថែម។ បន្ថែមពីលើនេះ ថ្លៃសេវាសម្រាប់ការជួញដូរមូលបត្រ មានកម្រិតទាប ដោយស្ថិតក្នុងរង្វង់ ០,៥% នៃតម្លៃជួញដូរតែប៉ុណ្ណោះ។

### ១.៤.២ គុណវិបត្តិនៃទីផ្សារមូលបត្រ

បើទោះជាទីផ្សារមូលបត្រ បានពាំនាំអត្ថប្រយោជន៍ដ៏សំបូរបែបដល់សេដ្ឋកិច្ចជាតិក៏ពិតមែន ស្របពេលនេះដែរទីផ្សារក៏មានគុណវិបត្តិមួយចំនួនដែលគួរយល់ដឹង។ ពិសេសចំពោះប្រទេសដែលមានប្រព័ន្ធច្បាប់ទន់ខ្សោយ គឺតែងតែជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោម[8]៖

- **ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់** គឺជាការជួញដូរមួយដែលមានការគិតគូរយ៉ាងម៉ត់ចត់ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យមួយចំនួនដែលវិនិយោគិនអាចនឹងទទួលការខាតបង់។ ការឆក់ឱកាសទិញ លក់មូលបត្រនេះ គឺជាការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថាតម្លៃភាគហ៊ុននឹងកើនឡើងក្នុងពេលអនាគត ហើយទទួលបានប្រាក់ចំណេញក្នុងមួយលើកៗ។ ការឆក់ឱកាសទិញ លក់របៀបនេះនឹងជះឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ការទិញលក់បែបនេះ នឹងធ្វើឲ្យមានភាគហ៊ុននៅលើទីផ្សារមានភាពខ្វះ ឬលើសនៅពេលដែលមានការត្រូវរ៉ូវគ្នារវាងអ្នកលក់ និងអ្នកទិញច្រើន។ ព្រឹត្តិការណ៍នេះក៏ធ្វើឲ្យតម្លៃភាគហ៊ុនលើទីផ្សារមូលបត្រមានចលនាកើនឡើង និងធ្លាក់ចុះផងដែរ។
- **ការជួញដូរផ្ទៃក្នុង** មានបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីមួយចំនួនបានលួចយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរដើម្បីរកប្រាក់ចំណេញផ្ទាល់ខ្លួន ដែលជាហេតុធ្វើឲ្យតម្លៃនៃទីផ្សារភាគហ៊ុនប្រែប្រួល ហើយព័ត៌មាននោះសុទ្ធតែមិនមែនជាព័ត៌មានសាធារណៈ ពោលគឺព័ត៌មានសម្ងាត់។
- **ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ** គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេសមិនធ្វើសកម្មភាពណាមួយដែលបណ្តាលឲ្យ ឬ អាចបណ្តាលឲ្យមានលក្ខណៈក្លែងបន្លំ ឆបោក ឬនាំឲ្យមានការយល់ខុស ចំពោះរបៀបនៃការជួញដូរមូលបត្រ ឬការធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។
- **សេចក្តីថ្លែងការណ៍ ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ** ឬដែលនាំឲ្យមានការយល់ខុសទាំងស្រុងទៅលើការជួញដូរមូលបត្រ ដែលធ្វើឲ្យមហាជនខាតបង់ពីការក្លែងបន្លំនេះ ឬបណ្តាលឲ្យមានការកើនឡើង ឬថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

[8] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយមូលបត្រតម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និង អភិបាលកិច្ចសាជីវកម្មល្អ ដែលអាចធ្វើជាបន្ទុកមួយដ៏ល្អសម្រាប់វិនិយោគិនបង្កើនការទុកចិត្តក្នុង ការបណ្តាក់ទុនទៅលើក្រុមហ៊ុន។ ម៉្យាងទៀត ក្រុមហ៊ុននឹងបានផ្លែផ្កាមកវិញនូវទុន រយៈពេលវែង ក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

## ១.៥ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ

បច្ចុប្បន្ន អ្នកចូលរួមក្នុងទីផ្សារមូលបត្រត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោម[9]៖

### ១.៥.១ តួអង្គលើទីផ្សារដំបូង

#### ១.៥.១.១ ក្រុមហ៊ុនធានាទិញមូលបត្រ

នៅក្នុងទីផ្សារភាគហ៊ុនក្រុមហ៊ុនធានាទិញមូលបត្រ ជាក្រុមហ៊ុនសហកម្មសិទ្ធិទទួលអាជ្ញា-ប័ណ្ណពីគ.ម.ក. ដែលមានតួនាទីក្នុងការមើលខុសត្រូវនូវការបោះផ្សាយជាសាធារណៈ និងការចែក ចាយមូលបត្រ (នៅក្នុងទម្រង់ជាប័ណ្ណភាគហ៊ុនធម្មតា ឬភាគហ៊ុនអាទិភាព) របស់សាជីវកម្ម ឬ ស្ថា-ប័នដែលធ្វើការបោះផ្សាយ។ តួនាទីលេចធ្លោបំផុតរបស់ក្រុមហ៊ុនធានាទិញមូលបត្រគឺ ការផ្តល់ ប្រឹក្សាក្នុងដំណើរការបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង (Initial Public Offering)។ IPO គឺជាដំណើរការនៃការលក់ភាគហ៊ុនរបស់ក្រុមហ៊ុនឯកជន នៅលើផ្សារហ៊ុនសាធារណៈជាលើក ដំបូង។ ក្រុមហ៊ុនធានាទិញមូលបត្រ គឺជាអ្នកឯកទេសផ្នែកហិរញ្ញវត្ថុដែលធ្វើការយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នបោះផ្សាយដើម្បីកំណត់ថ្លៃលក់មូលបត្រដំបូង (Pricing) ទំហំទឹកប្រាក់នៃមូលបត្រ (Issue Amount) ចំនួនមូលបត្របោះផ្សាយ (Number of Securities Issued) និងពេលវេលានៃការ បោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution Timeline) ទៅវិនិយោគិនតាមរយៈបណ្តាញ ចែកចាយរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។

ក្រុមហ៊ុនធានាទិញមូលបត្រជាទូទៅជាធនាគារវិនិយោគ ដែលមានអ្នកឯកទេស IPO។ ធនាគារវិនិយោគទាំងនេះមាន ទំនាក់ទំនងជាមួយបណ្តាញនៃអង្គភាពវិនិយោគទុនធំ ៗ ជាច្រើន ដូចជា មូលនិធិសង្គម និងក្រុមហ៊ុនធានារ៉ាប់រងដើម្បីវាស់ស្ទង់ពីផលប្រយោជន៍នៃគារវិនិយោគ[10]។ ចំនួនការប្រាក់ដែលវិនិយោគិនទាំងនេះទទួលបាន ជួយឱ្យក្រុមហ៊ុនធានាទិញមូលបត្រអាចកំណត់ តម្លៃ IPO នៃភាគហ៊ុន។ ក្រៅពីនេះ ក្រុមហ៊ុនធានាទិញមូលបត្រមានតួនាទីផ្សេងទៀតដូចជា៖

[9] សៀវ សុស៊ីខា (២០១៧), *កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា*

[10] https://www.investopedia.com/terms/u/underwriter.asp

- ទិញមូលបត្រទាំងអស់ ឬ មួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដើម្បីធានានូវភាពជោគជ័យរបស់ក្រុមហ៊ុនបោះផ្សាយនោះ។
- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬ ចូលរួមដោយផ្ទាល់ ឬ មិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- លើសពីនេះក្រុមហ៊ុនធានាទិញមូលបត្រ អាចធ្វើអាជីវកម្មមូលបត្រផ្សេងទៀតដូចជា អាជីវកម្មជួញដូរមូលបត្រ អាជីវកម្ម ឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ បច្ចុប្បន្នក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter)នៅកម្ពុជារួមមាន[11]៖
  - ➢ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc.)
  - ➢ អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក (RHB Indochina Securities PLC.)
  - ➢ កាណា ស៊ីឃ្យូរីធី អិលធីឌី (Cana Securities Ltd.)
  - ➢ កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (Campu Securities Plc.)
  - ➢ អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI Royal Securities Plc.)
  - ➢ ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

#### ១.៥.១.២ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ បានដល់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបានស្នើសុំ ឬ បានបោះផ្សាយលក់មូលបត្រជាសាធារណៈ។

- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- នីតិបុគ្គលប្រតិស្រុត **(Permitted Entity)** សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុ-ជា ស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ នីតិបុគ្គលនេះ មិនមែនជាក្រុមហ៊ុន

---

[11] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *អន្តរការីទីផ្សារៈ ក្រុមហ៊ុនធានាទិញមូលបត្រ*

មហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជាទេ[12]។

**១.៥.១.៣ វិនិយោគិន**

វិនិយោគិនសំដៅដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិធ្វើការទិញ ឬ លក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈនៅលើទីផ្សារមូលបត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១.៥.២ តួអង្គលើទីផ្សារបន្ទាប់

### ១.៥.២.១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នៅក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ។

**ក. ប្រតិបត្តិករទីផ្សារមូលបត្រ**

ប្រតិបត្តិករទីផ្សារមូលបត្រ ជានិយ័តករជួរមុខ ក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ និងធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជា៖

- ការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬ ដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបន្ស៊ីលើប្រតិបត្តិការបញ្ជាទិញ លក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬ មធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬ អេឡិចត្រូនិច។
- សកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយគ.ម.ក.។

ប្រតិបត្តិករនេះ មានតួនាទីផ្គូរផ្គងតម្លៃរវាងអ្នកលក់ និងអ្នកទិញ ដើម្បីរកតម្លៃមួយឲ្យត្រូវគ្នាដោយផ្តល់អាទិភាពដល់អ្នកលក់ដែលដាក់តម្លៃទាបជាងគេ។

អាទិភាពនៃការផ្គូរផ្គងនេះ គឺផ្តោតទៅលើតម្លៃពោលគឺ ចំពោះអ្នកទិញណាដែលហ៊ានឲ្យថ្លៃខ្ពស់ គេនឹងទទួលបានមុន ហើយអ្នកលក់ណាដែលហ៊ានលក់ក្នុងតម្លៃទាប គេនឹងទទួលបានមុន។ ក្នុងករណីតម្លៃដូចគ្នា គេពិនិត្យមើលលើពេលវេលា។ បើពេលដូចគ្នាទៀត គេមើលលើបរិមាណ។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.២៥%។

[12]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, មាត្រា ៣៨

**ខ. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ**

ប្រតិបត្តិករនេះ ជាអ្នកធានាថាមូលបត្របានដល់ដៃអ្នកទិញ ហើយលុយបានដល់ដៃអ្នកលក់ក្នុងពេលតែមួយ ក្រោយពីការផ្គូរផ្គងទទួលបានជោគជ័យ។

ប្រតិបត្តិករនេះ ក៏ធ្វើការត្រួតពិនិត្យមូលបត្រខាងអ្នកលក់ (ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់លក់ ឬ ទេ) និងខាងលក់ទិញ (តើមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញ ឬ ទេ) ដើម្បីបញ្ចៀសនូវហានិភ័យការទូទាត់។

គេដកសាច់ប្រាក់ពីអ្នកទិញ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលមាន ដូចជា ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និងធនាគារ ប៊ី អាយ ឌី ស៊ី។ គេដកមូលបត្រពីអ្នកលក់ តាមរយៈប្រតិបត្តិកររក្សាទុកមូលបត្រ។ ការផាត់ទាត់ធ្វើឡើងនៅ ២ ថ្ងៃក្រោយបន្ទាប់ពីថ្ងៃជួញដូរ (T+2)។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.១%។

**គ. ប្រតិបត្តិកររក្សាទុកមូលបត្រ**

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលយល់ព្រមជាមួយបុគ្គលមួយទៀតដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្ម ដូចខាងក្រោមនេះ ទោះជាអតិថិជនធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬ ធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ៖

- កាន់កាប់ ឬ ចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃផ្សេងទៀត ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
- ទទួលរក្សាទុកមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃផ្សេងទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬ ជាទម្រង់អរូបី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
- ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងទៀត ដែលទាក់ទងនឹងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ (ក) និង (ខ)។

ប្រតិបត្តិករនេះ ជាអ្នករក្សាទុកមូលបត្រជូនវិនិយោគិន ព្រោះវិនិយោគិនមិនអាចយកមូល-បត្រមកទុកនៅគេហដ្ឋានរបស់ខ្លួនបានឡើយ។ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.១%។

**១.៥.២.២ វិនិយោគិន**

វិនិយោគិននៅក្នុងទីផ្សារបន្ទាប់ក៏ដូចជា វិនិយោគិននៅក្នុងទីផ្សារដំបូងគឺសំដៅដល់លើសា-ធារណៈជនទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ឬ វិនិយោគិនជាបុគ្គល និងវិនិយោគិនជាស្ថាប័នដែលធ្វើការទិញ លក់មូលបត្រ។

#### ១.៥.២.៣ ក្រុមហ៊ុនមូលបត្រ

ក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនបោះផ្សាយមានតួនាទីជាអ្នកផ្តល់នូវឧបករណ៍ សម្រាប់ធ្វើការជួញដូរហើយបានលក់ទៅឲ្យវិនិយោគិន និងប្រមូលទុនក្នុងការពង្រីកអាជីវកម្ម។ ដូចនេះ ក្រុមហ៊ុនបោះផ្សាយតែងតាំងភ្នាក់ងារទូទាត់ក្នុងការបែងចែកភាគលាភ (Dividend) សម្រាប់ភាគហ៊ុនបង់ការប្រាក់ ឬ ប្រាក់ដើមសម្រាប់សញ្ញាប័ណ្ណ ដល់វិនិយោគិនដែលកាន់កាប់មូលបត្រនៅចុងគ្រា។

#### ១.៥.២.៤ អន្តរការីទីផ្សារ

អន្តរការីទីផ្សារមូលបត្រកម្ពុជា គឺជាបណ្តុំនៃអង្គភាព ឬ បុគ្គលទាំងឡាយដែលធ្វើការណែនាំ ក្រុមហ៊ុនបោះផ្សាយមូលបត្រទៅកាន់ទីផ្សារមូលបត្រ។ អន្តរការីទីផ្សារមូលបត្ររួមមានក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers) ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokers) ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisors) ក្រុមហ៊ុនសមភាគីកណ្តាល (Central Counterparty Companies) និងឈ្មួញជើងសាឧបករណ៍ និស្សន្ទ (Derivatives Brokers)។ល។ យោងតាមគណៈកម្មការមូលបត្រកម្ពុជា អន្តរការីទីផ្សារចែកជា[13]៖

- **ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter)** គឺជាស្ថាប័នដែលផ្តល់សេវាកម្ម សម្រាប់ការបោះផ្សាយលក់មូលបត្រ និងមានសិទ្ធិក្នុងការជួញដូរមូលបត្រតាមបញ្ជាអតិថិជន និងខ្លួនឯងផ្ទាល់។
- **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers)** គឺជាអ្នកធ្វើការទិញ លក់មូលបត្រដោយផ្ទាល់នៅលើទីផ្សារហិរញ្ញវត្ថុ (ធ្វើការជួញដូរតាមបញ្ជារបស់អតិថិជន និងមានសិទ្ធិក្នុងការជួញដូរផ្ទាល់ខ្លួន)។ បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealers) នៅកម្ពុជារួមមាន៖
  - ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី (Golden Fortune (Cambodia) Securities Plc.)
- **ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokers)** គឺជាអ្នកសម្របសម្រួលប្រតិបត្តិការទិញ លក់មូលបត្រដល់អតិថិជន។ ចំណូលរបស់ឈ្មួញជើងសារបានពីកម្រៃជើងសារប្រតិបត្តិការ នៅពេលដែលអតិថិជនធ្វើការបញ្ជាទិញ និងលក់ (មានសិទ្ធិជួញដូរតាមតែ

[13] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *អន្តរការីទីផ្សារ*

បញ្ហារបស់អតិថិជន)។ បច្ចុប្បន្នក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Brokers) នៅកម្ពុជារួមមាន៖

- ➢ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACLEDA Securities Plc.)
- ➢ ខេប ស៊ីឃ្យូរីធី លីមីធីត (CAB Securities Limited.)
- ➢ ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក (Cambodia-Vietnam Securities Co., Ltd.)

- **ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisors)** គឺដើរតួនាទីជាអ្នកផ្តល់យោបល់ក្នុងការវិនិយោគលើវិស័យមូលបត្រនេះ ហើយទទួលបានប្រាក់កម្រៃតាមរយៈការផ្តល់សេវាកម្មនេះ។ បច្ចុប្បន្នក្រុមហ៊ុនទីប្រឹក្សាវិនិយោគ (Investment Advisors) នៅកម្ពុជារួមមាន៖
  - ➢ អង្គរ ឃេភីថល អ៊ែតវ៉ាយហ្ស៊ឺរ (Angkor Capital Advisors Co., Ltd.)
  - ➢ អេហ្វ.យូ.ជី.អាយ ហ្គោល (F.U.G.I GOLD Co., Ltd.)
- **ក្រុមហ៊ុនសមភាគីកណ្តាល (Central Counterparty Companies)**
  - ➢ ខេមបូឌាន ដេរីវេ៉ទីវ អ៊ិចឆេង ឯ.ក (Cambodian Derivatives Exchange Co., LTD.)
  - ➢ ភ្នំពេញ ដេរីវេ៉ទីវ អិចឆេង ភីអិលស៊ី (Phnom Penh Derivative Exchange Plc.)
  - ➢ រ៉ូយ៉ាល់ ហ្វាយនែនសល ខបភើរេសិន (Royal Financial Corporation)
  - ➢ ហ្គោល ហ្វាយនេនសល គ្លូបិល អ៊ិនវេសម៉ិន (Gold Financial Global Investment)
- **ឈ្មួញជើងសាឧបករណ៍និស្សន្ទ (Derivatives Brokers)**
  - ➢ ខេមបូឌាន ដេរីវេ៉ទីវ អ៊ិចឆេង ឯ.ក (Cambodian Derivatives Exchange Co., LTD)
  - ➢ ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)
  - ➢ រ៉ូយ៉ាល់ ហ្វាយនែនសល ខបភើរេសិន (Royal Financial Corporation)
  - ➢ ហ្គោល ហ្វាយនេនសល គ្លូបិល អ៊ិនវេសម៉ិន (Gold Financial Global Investment)
  - ➢ ហ្គោលអេហ្វអិកស៍ អ៊ិនវេសម៉ិន (GoldFx Investment)
  - ➢ ភ្នំពេញ ដេរីវេ៉ទីវ អិចឆេង ភីអិលស៊ី (Phnom Penh Derivative Exchange Plc.)
  - ➢ អាស្កាព អ៊ែសិត មេនិចម៉ិន ឯ.ក (Askap Asset Management Co., Ltd)
  - ➢ ប្លែកវែល គ្លូបិល អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក (Blackwell Global Investment (Cambodia) Co., Ltd)
  - ➢ រីចវីល យេផេន ឯ.ក (Richwill Japan Co., Ltd.)
  - ➢ អាល់ហ្វា ហ្គោល ភ្យូឈើរ ឯ.ក (Alpha Gold Futures Co., Ltd.)

- ស្កាយ ប្រេសឹស មេថល (Sky Precious Metals Co., Ltd.)

### ១.៥.៣ តួអង្គចូលរួមដទៃផ្សេងទៀត

#### ១.៥.៣.១ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

- ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent) គឺសំដៅដល់បុគ្គលដែលមានតួនាទីគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ ដែលពាក់ព័ន្ធនឹងមូលបត្រ។ បច្ចុប្បន្ននៅប្រទេសកម្ពុជារួមមាន៖
  - ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
  - ធនាគារ កាណាឌីយ៉ា ក.អ (Canadia Bank Plc.)
  - ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (Bank for Investment and Development of Cambodia Plc.)

#### ១.៥.៣.២ ភ្នាក់ងារបញ្ជិកាមូលបត្រ

ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលផ្តល់សេវាកម្មក្នុងការរៀបចំកត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រជូនក្រុមហ៊ុនបោះផ្សាយមូលបត្រដូចខាងក្រោម៖

១. វិនិយោគិនត្រូវចុះឈ្មោះទិញមូលបត្រតាមរយៈក្រុមហ៊ុនធានាទិញមូលបត្រ។

២. ក្រុមហ៊ុនមូលបត្របញ្ជូនពាក្យស្នើសុំធ្វើបរិវិសកម្ម និងឯកសារពាក់ព័ន្ធរបស់វិនិយោគិនទៅភ្នាក់ងារបញ្ជិកាមូលបត្រ។

៣. ភ្នាក់ងារបញ្ជិកាមូលបត្ររៀបចំឯកសារពាក់ព័ន្ធនឹងការធ្វើបរិវិសកម្ម។

៤. ភ្នាក់ងារបញ្ជិកាមូលបត្រធ្វើការផ្ទៀងផ្ទាត់ពីទំហំ នៃការធ្វើបរិវិសកម្មរបស់វិនិយោគិននីមួយៗ និងធ្វើការពិនិត្យ ពីភាពត្រឹមត្រូវនៃចំនួនទឹកប្រាក់ទៅតាមចំនួនមូលបត្រ ដែលបានធ្វើបរិវិសកម្មនីមួយៗក្រោយពីទទួលបានសំណុំបែបបទនៃការធ្វើបរិវិសកម្មពីក្រុមហ៊ុនធានាទិញមូលបត្រ។

៥. ភ្នាក់ងារបញ្ជិកាមូលបត្រ ធ្វើការបូកសរុបបញ្ជីឈ្មោះអ្នកធ្វើបរិវិសកម្ម និងចំនួនមូលបត្រដែលបានធ្វើបរិវិសកម្មដើម្បីបែងចែកមូលបត្របន្ទាប់ពីរយៈពេលធ្វើបរិវិសកម្មបានបញ្ចប់។

៦. តាមរយៈការបូកសរុបបញ្ជីនេះ ភ្នាក់ងារបញ្ជិកាមូលបត្រអាចកំណត់យ៉ាងច្បាស់លាស់ថា ការធ្វើបរិវិសកម្មនេះជាប្រភេទ Over-subscription ឬ Under-subscription។

- ក្នុងករណីបរិមាណបរិវិសកម្មលើសពីចំនួនមូលបត្រ ដែលបោះផ្សាយលក់ជាសាធារណៈ (Over-subscription) ភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវចាប់ផ្តើមនីតិវិធីបែងចែកដោយមិនរើសអើង ដល់អ្នកធ្វើបរិវិសកម្មទៅតាមវិធីសាស្ត្រសមាមាត្រ (Pro Rata) ដោយកំណត់

ចំនួនមូលបត្រអប្បបរមា ដែលត្រូវបែងចែកឲ្យអ្នកធ្វើបរិវិសកម្ម ដែលបំពេញបែបបទត្រឹមត្រូវដោយមានការចូលរួមពីក្រុមហ៊ុនធានាទិញមូលបត្រ។

- ក្នុងករណីបរិមាណបរិវិសកម្មតិចជាងចំនួនមូលបត្រ ដែលបោះផ្សាយលក់ជាសាធារណៈ (Under-subscription) ក្រុមហ៊ុនធានាទិញ ជាអ្នកទទួលខុសត្រូវទិញយកមូលបត្រដែលនៅសល់ទៅតាមតម្លៃ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងធានាទិញ ជាមួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

### ១.៥.៣.៣ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

- ភ្នាក់ងាចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent) សំដៅដល់បុគ្គលដែលត្រូវបានតែងតាំងដោយក្រុមហ៊ុនបោះផ្សាយ ដើម្បីរក្សាបញ្ជីកម្មសិទ្ធិករ បញ្ជីគណនេយ្យ និងបញ្ជីប្រតិបត្តិការ។
- ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលបានការទូទាត់មូលបត្រពីក្រុម-ហ៊ុនបោះផ្សាយ ហើយធ្វើការបែងចែកការទូទាត់នោះទៅឲ្យកម្មសិទ្ធិករមូលបត្រ។ បច្ចុប្បន្ននៅកម្ពុជារួមមាន៖
  - ធនាគារ អេស៊ីលីដា ភីអិលស៊ី (Acleda Bank Plc.)
  - ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី (Tricor Securities Services PLC.)
  - ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities PLC.)

### ១.៥.៣.៤ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់លើវិស័យមូលបត្រ

បច្ចុប្បន្នក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់លើវិស័យមូលបត្រ ដែលទទួលស្គាល់ពីគ.ម.ក. រួមមានដូចជា៖

- ក្រុមហ៊ុនមេធាវី អេច ប៊ី អេស (HBS LAW FIRM)
- ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង (R&T SOK & HENG LAW OFFICE)
- ការិយាល័យមេធាវី សុក ស៊ីផាន់ណា និង សហការីជាសមាជិក ZICOLAW (SOK SIPHANA & ASSOCIATES, A MEMBER OF ZICOLAW)
- ការិយាល័យមេធាវី សិទ្ធិស័ក្តិ (SITHISAK LAW OFFICE)
- ក្រុមមេធាវី អាស៊ី កម្ពុជា (ASIA CAMBODIA LAW FIRM)
- ការិយាល័យមេធាវី ប៊ុន និង សហការី (BUN & ASSOCATES)

- ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី (PYT & Associates LAW OFFICE)
- ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា (CSL & ASSOCIATES LAW OFFICE)
- ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន (HML LAW GROUP & CONSULTANTS)
- ការិយាល័យមេធាវី ភី អេន អេ អេស៊ា (P & A Asia Law Office)
- ការិយាល័យមេធាវី ស៊ិន & ផាតនើ (SIN & Partners Law Office)
- ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល) (CAMBODIA BAYON LAW GROUP)
- ក្រុមមេធាវី មេគង្គ (Mekong Law Group)

**១.៥.៣.៥ ក្រុមហ៊ុនផ្តល់សេវាបកប្រែផ្នែកមូលបត្រ**

- ក្រុមហ៊ុនពីរ៉ាមីត សឺវីស (PYRAMID SERVICE Co., Ltd)
- មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា (H.B.S NOTARY PUBLIC OF THE KINGDOM OF CAMBODIA)

**១.៥.៣.៦ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មជាក្រុមហ៊ុនដែលៈ

- ទទួលបានការទទួលស្គាល់ពី គ.ម.ក. ក្នុងការផ្តល់សេវាសវនកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។
- ធានាថាក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រអនុវត្តនូវស្តង់ដារគណនេយ្យបានត្រឹមត្រូវ
- ផ្តល់នូវរបាយការណ៍គណនេយ្យដែលអាចជឿជាក់បាន
- ផ្តល់នូវសុវត្ថិភាពខាងគ្រប់គ្រងគណនេយ្យ។

បច្ចុប្បន្ននៅកម្ពុជា មានក្រុមហ៊ុនមួយចំនួនដូចជាៈ

- ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា) (PricewaterhouseCoopers (Cambodia) Ltd. )
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា (KPMG CAMBODIA LTD)
- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត (BDO CAMBODIA LIMITED)
- ក្រុមហ៊ុន អឺនស្ទ៍ អែន យ៉ាំង (ខេមបូឌា) (ERNST & YOUNG (CAMBODIA) LTD.)

- ក្រុមហ៊ុន អង្គរ សឺធីហ្វាយ អឹខោនថឹន ណេតវើក អិមស៊ី មីលលែន វូដ (ខេមបូឌា) (Angkor Certified Accountant Network MC Millan Woods (Cambodia) Co., Ltd)
- ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត (Grant Thornton (Cambodia) Limited.)
- ក្រុមហ៊ុន ក្រូវ ហ័រវ៉ាត(ខេអេច) អិលធីឌី (Crowe Horwath (KH) Ltd.)
- ក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី (DELOITTE (CAMBODIA) CO., LTD)

**១.៥.៣.៧ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ**

បច្ចុប្បន្ននៅកម្ពុជា មានក្រុមហ៊ុនមួយចំនួនដូចជា៖

- ក្រុមហ៊ុន វីត្រាស់ អឺព្រេហ្សល (VTRUST APPRAISAL Co., Ltd.)
- ក្រុមហ៊ុន រៀល អ៊ីស្ទេត វី.អិម.ស៊ី (ខេមបូឌា) អិលធីឌី (REAL ESTATE V.M.C (Cambodia) Ltd)
- ក្រុមហ៊ុន ស៊ីប៊ី រីឆាត អ៊ែលលីស (ខេមបូឌា)ខមភេនី លីមីធីត (CB RICHARD ELLIS(CAMBODIA) COMPANY LIMITED)
- ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា) (Knight Frank (Cambodia) Pte., Ltd)

# ជំពូកទី ២

# គណៈកម្មការមូលបត្រ

# កម្ពុជា

# ជំពូកទី ២

# គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក. ត្រូវបានធ្វើឡើងដោយ អនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៨។

## ២.១ គោលដៅ និងគោលបំណងរបស់គ.ម.ក.

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)មានគោលដៅ និងគោលបំណងដូចខាងក្រោមៈ

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ បូករួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

## ២.២ ចក្ខុវិស័យ និងបេសកកម្មរបស់គ.ម.ក.

### ២.២.១ ចក្ខុវិស័យ

គណៈកម្មការមូលត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្ដីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មាន គោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំ ណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូល-បត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា[14]។

### ២.២.២ បេសកកម្ម

គ.ម.ក. មានបេសកកម្មក្នុងវិស័យមូលបត្រនៅកម្ពុជាដូចតទៅ៖

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការ ការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរ មូលបត្រប្រកបដោយសណ្ដាប់ ធ្នាប់ និង ត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរា-ជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណា-ចក្រកម្ពុជា។

## ២.៣ ប្រធាន និងសមាជិករបស់គ.ម.ក.

គណៈកម្មការមូលបត្រកម្ពុជា មានប្រធានមួយរូប និងសមាជិកចំនួន ៨រូប។ ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គ.ម.ក. មានសមាជិក៨រូបដូចខាងក្រោម៖

១. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប

២. តំណាងធនាគារជាតិកម្ពុជា ០១រូប

[14] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *ចក្ខុវិស័យ និងបេសកកម្ម*

៣. តំណាងក្រសួងពាណិជ្ជកម្ម ០១រូប

៤. តំណាងក្រសួងយុត្តិធម៌ ០១រូប

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប

៦. អគ្គនាយកនៃ គ.ម.ក. ០១ រូប

៧. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២រូប

### ២.៤ ទីតាំងរបស់គ.ម.ក.

គណៈកម្មការមូលបត្រកម្ពុជាមានទីតាំងនៅផ្ទះលេខ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### ២.៥ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជាមានដូចខាងក្រោម[15]៖

#### ២.៥.១ រូបសញ្ញា

- រូបហង្សពណ៌មាស។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌ទឹកមាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។

រូបភាពទី ២.១: រូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

[15] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា*។

### ២.៥.២ អត្ថន័យនៃរូបសញ្ញា

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ មូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យ ភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃ ពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួត ពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និង តម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច- ជាតិ។

### ២.៥.៣ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា

ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា"គណៈកម្មការមូលបត្រកម្ពុជា "។

រូបភាពទី ២.២: ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា



## ២.៦ រចនាសម្ព័ន្ធអង្គភាពចាត់តាំងគ.ម.ក.

គ.ម.ក. ដឹកនាំដោយអគ្គនាយក០១រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងមានអគ្គនាយករងមួយចំនួនជាជំនួយការ។

គ.ម.ក.មាននាយកដ្ឋានចំណុះចំនួន០៦ដូចខាងក្រោម៖

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៦. នាយកដ្ឋានកិច្ចការគតិយុត្ត គ.ម.ក. មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក.

រូបភាពទី ២.៣: រចនាសម្ព័ន្ធនៃគណៈកម្មការមូលបត្រកម្ពុជា



# ជំពូកទី ៣

# ក្រុមហ៊ុនផ្សារមូលបត្រ

# កម្ពុជា

# ជំពូកទី ៣

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ផ្សារមូលបត្រ គឺជាកន្លែងដែលមូលបត្រ មានដូចជាភាគហ៊ុន សញ្ញាបណ្ណ និងឧបករណ៍ដេរីវេទីវត្រូវបានទិញនិងលក់។ ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ(ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមានវាទៅអ្នកដែលត្រូវការវាប្រកបដោយប្រសិទ្ធភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្មនិងពាណិជ្ជកម្ម នឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឱ្យមានការងារ និងទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។

## ៣.១ ចក្ខុវិស័យ និងបេសកកម្ម

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចក្ខុវិស័យ និងបេសកកម្មដូចតទៅ[16]៖

### ៣.១.១ ចក្ខុវិស័យ

ដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

### ៣.១.២ បេសកកម្ម

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុនឯកជន និងសាធារណៈនៅក្នុងប្រទេសកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រ ដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេសកម្ពុជា
- ដើម្បីបង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបច្រើនប្រភេទ សម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការសហគ្រាសសាធារណៈមួយដែលមានស្វ័យចីរភាព ក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

[16] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០១៨), *ចក្ខុវិស័យ និងបេសកកម្ម*

## ៣.២ ប្រវត្តិនៃផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូល-បត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនា-បតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្ស-រណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា"ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របទៅតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃចំនួនភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុប។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន[17]។




[17] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០១៨), *ប្រវត្តិផ.ម.ក.*

- **នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២**

ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

- **នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១**

ការទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ពី គ.ម.ក។

- **នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០**

ចុះបញ្ជីពាណិជ្ជកម្ម។

- **នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩**

កិច្ចព្រមព្រៀង **"ក្រុមហ៊ុនចំរុះ"** រវាងរាជរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

- **នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨**

អនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

- **នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧**

ការដាក់អោយដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា។

- **នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦**

អនុស្សរណៈយោគយល់អំពីការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

## ៣.២ រចនាសម្ព័ន្ធនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដឹកនាំដោយអគ្គនាយក០១រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងមានអគ្គនាយករងមួយជាជំនួយការ[18]។

[18] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០១៨), *រចនាសម្ព័ន្ធគ្រប់គ្រង*

រូបភាពទី ៣.១: រចនាសម្ព័ន្ធនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា




ផ.ម.ក.មាននាយកដ្ឋានចំណុះចំនួន០៦ដូចខាងក្រោម៖

- នាយកដ្ឋានប្រតិបត្តិការទីផ្សារមូលបត្រ
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានផាត់ទាត់ និងទូទាត់មូលបត្រ
- នាយកដ្ឋានរក្សាទុកមូលបត្រ
- នាយកដ្ឋានចុះបញ្ជី និងការផ្តល់ព័ត៌មាន
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

❖ **ក្រុមប្រឹក្សាភិបាល**

- ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និង អគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

- សមាជិកចំនួន ៨រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

រូបភាពទី ៣.២: ក្រុមប្រឹក្សានៃផ្សារមូលបត្រកម្ពុជា



# ជំពូកទី ៤

# ដំណើរការជួញដូរមូលបត្រ លើទីផ្សារមូលបត្រកម្ពុជា

# ជំពូកទី ៤

# ដំណើរការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា

## ៤.១ ការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា

ដើម្បីជាជំនួយដល់ភាពងាយស្រួលនៃការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា វិនិយោគិនគួរយល់ដឹងអំពីនីតិវិធីនៃការជួញដូរមូលបត្រ និងដំណើរការប្រតិបត្តិរបស់ទីផ្សារជាមុនសិន។

### ៤.១.១ នីតិវិធីនៃការជួញដូរមូលបត្រ

ចំពោះសាធារណៈជន ដែលមានបំណងធ្វើការជួញដូរមូលបត្រកម្មសិទ្ធិនៅលើទីផ្សារមូល-បត្រកម្ពុជា នោះត្រូវអនុវត្តនូវជំហានដូចខាងក្រោម[19]៖

#### ៤.១.១.១ ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

មុននឹងធ្វើការវិនិយោគលើទីផ្សារ វិនិយោគិនត្រូវធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. ។ ការស្នើសុំអាចធ្វើឡើង ដោយសាមីខ្លួនវិនិយោគិនផ្ទាល់ទៅ គ.ម.ក. ឬ តាមរយៈក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើសរួច។ ក្នុងនោះ គ.ម.ក. តម្រូវឲ្យរូបវន្តបុគ្គលបង់ថ្លៃសេវាចំនួន ២០,០០០ រៀល និង នីតិបុគ្គលត្រូវបង់សេវាចំនួន ៥០,០០០ រៀល។ គណៈកម្មការមូលបត្រកម្ពុជានឹងផ្តល់ជូននូវលេខអត្តសញ្ញាណវិនិយោគិនដោយផ្ទាល់ ឬ តាមរយៈក្រុមហ៊ុនមូលបត្រ ក្នុងរយៈពេល ០២ ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមទម្រង់អេឡិចត្រូនិច (Soft Copy) ឬ រយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមទម្រង់បោះពុម្ព ()។ លេខអត្តសញ្ញាណវិនិយោគិន មានសុពលភាពរយៈពេល ១០ ឆ្នាំគិតចាប់ពីថ្ងៃដែល គ.ម.ក. បានផ្តល់ជូនលេខអត្តសញ្ញាណដល់វិនិយោគិន។ វិនិយោគិនអាចបន្តការប្រើប្រាស់ លេខអត្តសញ្ញាណវិនិយោគិនបាន ដោយការដាក់ពាក្យស្នើសុំបន្តការប្រើប្រាស់ ក្នុងរយៈពេល ០៣ ខែមុនថ្ងៃផុតកំណត់។

#### ៤.១.១.២ ការបើកគណនីជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនត្រូវធ្វើការបំពេញ ពាក្យស្នើសុំបើកគណនីជួញដូរ និងចុះកិច្ចព្រមព្រៀងអតិថិជននៅក្រុមហ៊ុនមូលបត្រណាមួយដែលជាសមាជិករបស់ ផ.ម.ក. នៅមួយថ្ងៃមុនថ្ងៃជួញដូរ។ ការបើកគណនីជួញដូរនោះ វិនិយោគិនមានសិទ្ធិបើក

[19] ផ្សារមូលបត្រកម្ពុជា (២០១៤), *ប្រតិបត្តិការរបស់ផ.ម.ក., នីតិវិធីមូលដ្ឋាននៃការជួញដូរ*

គណនីតែមួយ នៅក្នុងក្រុមហ៊ុនមូលបត្រមួយ។ នៅពេលគណនីបានបើករួច វិនិយោគិនត្រូវរង់ចាំដល់ថ្ងៃធ្វើការបន្ទាប់ ទើបអាចដាក់បញ្ជាជួញដូរបាន[20]។

### ៤.១.១.៣ ការដាក់បញ្ជាជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន និង បានបើកគណនីជួញដូរមូលបត្ររួច ហើយ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ លក់មូលបត្រ តាមរយៈក្រុមហ៊ុនមូលបត្រទៅកាន់ ផ.ម .ក. បាន។ ប៉ុន្តែមុននឹងដាក់បញ្ជាបាន វិនិយោគិនត្រូវមានសាច់ប្រាក់យ៉ាងហោចណាស់ ១០០% (សម្រាប់បញ្ជាទិញ) និងមានមូលបត្រយ៉ាងហោចណាស់ ១០០% (សម្រាប់បញ្ជាលក់) នៃបញ្ជាសរុប។ នៅពេលបញ្ជាត្រូវបានបញ្ជូន សាច់ប្រាក់ និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកដោយក្រុមហ៊ុនមូលបត្រ ក្នុងគោលបំណងដើម្បីទូទាត់ ឬ បង្កកទុករហូតដល់បញ្ជាអស់សុពលភាព។

❖ **មធ្យោបាយនៃការដាក់បញ្ជា**

វិនិយោគិនអាចដាក់បញ្ជាទៅកាន់ក្រុមហ៊ុនមូលបត្រតាមរយៈវិធីសាស្ត្រដូចជា៖

- ដាក់បញ្ជាដោយផ្ទាល់នៅក្រុមហ៊ុនមូលបត្រ
- ឯកសារជាលាយលក្ខណ៍អក្សរ
- ពាក្យសម្តី
- មធ្យោបាយអេឡិចត្រូនិចដទៃទៀតដូចជា អ៊ីម៉ែល ទូរស័ព្ទ ទូរសារ ឬ សារទូរស័ព្ទ។

❖ **ព័ត៌មាននៃការដាក់បញ្ជា**

ព័ត៌មានដែលអតិថិជនត្រូវផ្តល់ទៅឲ្យក្រុមហ៊ុនមូលបត្រ ឬ ភ្នាក់ងារក្រុមហ៊ុនមូលបត្រនៅពេលដែលដាក់បញ្ជារួមមាន៖

- ឈ្មោះវិនិយោគិន
- លេខអត្តសញ្ញាណវិនិយោគិន
- លេខគណនីជួញដូរ
- ឈ្មោះមូលបត្រ
- ប្រភេទបញ្ជា (ទិញ លក់ កែប្រែ ឬ លុប)
- លេខបញ្ជាដើមក្នុងករណីជាបញ្ជាកែប្រែ ឬ លុប
- បរិមាណ
- ថ្លៃ។

[20] គណៈកម្មការមូលបត្រកម្ពុជា (២០១២), *គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន*

នៅពេលដែលទទួលបានបញ្ជាពីអតិថិជន ក្រុមហ៊ុនមូលបត្រ ត្រូវផ្ទៀតផ្ទាត់សារពើឡើងវិញនូវសិទ្ធិរបស់បុគ្គលដែលបានដាក់បញ្ជា និងធ្វើការបញ្ជាក់ដោយផ្ទាល់ពីអតិថិជនពីបញ្ជានោះដោយឲ្យអតិថិជនធ្វើការបំពេញបណ្ណបញ្ជាជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាទុកជាភស្តុតាងនៃការបញ្ជា។ ចំពោះបញ្ជាតាមទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬ អ៊ីម៉ែល ក្រុមហ៊ុនមូលបត្រ ត្រូវធ្វើការថតទុកសម្លេងនៃអតិថិជនរាល់បញ្ជានេះទាំងអស់។ ក្រុមហ៊ុនមូលបត្រត្រូវរក្សាទុកក្នុងទម្រង់ដើមរបស់ភស្តុតាងស្តីពីព័ត៌មាននៃការអនុវត្តបញ្ជាទាំងនោះ យ៉ាងតិចរយៈពេល ១០ ឆ្នាំ[21]។

❖ **សុពលភាពនៃបញ្ជា**

បញ្ជានីមួយៗមានសុពលភាពចាប់ពីពេលដែលទទួលបាន ក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះ ត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។ ប្រសិនបើអតិថិជនធ្វើការដាក់បញ្ជាក្នុងវគ្គជួញដូរទីមួយ (ម៉ោង ៨:៣០) តែមិនបានសម្រេច នោះបញ្ជារបស់គាត់នៅតែមានសុពលភាពក្នុងវគ្គជួញដូរទីពីរ (ម៉ោង ១១:៣០) ម្តងទៀត ក៏ប៉ុន្តែបើក្នុងវគ្គជួញដូរនេះមិនបានសម្រេចទៀត នោះបញ្ជានឹងអស់សុពលភាពត្រឹមថ្ងៃជួញដូរនោះ។

❖ **ការលុបចោល ឬ កែប្រែបញ្ជា**

ការកែប្រែ ឬ លុបចោលបញ្ជាអាចធ្វើទៅបាន ដរាបណាបញ្ជានោះមិនទាន់ត្រូវបានអនុវត្ត។ ពេលវេលាបញ្ជាក់ពីការទទួលបញ្ជានៅក្នុងប្រព័ន្ធជួញដូរ របស់ផ.ម.ក. ត្រូវកំណត់សាជាថ្មីនៅពេលដែលមានការកែប្រែថ្លៃ ឬ ការបង្កើនបរិមាណនៃបញ្ជា។

### ៤.១.២ ដំណើរការប្រតិបត្តិការទីផ្សារ

#### ៤.១.២.១ ពេលវេលានៃការជួញដូរ

ផ្សារមូលបត្រកម្ពុជា អនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិដូចខាងក្រោម៖

- ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។
- ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ ១១:៣០ ព្រឹក។
- ការអនុវត្តការជួញដូរ ឬ ការផ្គូផ្គងធ្វើឡើង ០៦ (ប្រាំមួយ) ដងក្នុងមួយថ្ងៃគឺ៖
    - ➢ ការផ្គូរផ្គងលើកទី១ នៅម៉ោង ៩:០០ ព្រឹក
    - ➢ ការផ្គូរផ្គងលើកទី២ នៅម៉ោង ៩:៣០ ព្រឹក
    - ➢ ការផ្គូរផ្គងលើកទី៣ នៅម៉ោង ១០:០០ ព្រឹក
    - ➢ ការផ្គូរផ្គងលើកទី៤ នៅម៉ោង ១០:៣០ ព្រឹក

[21] គណៈកម្មការមូលបត្រកម្ពុជា (២០១៤), *គោលការណ៍ណែនាំស្តីពីយន្តការនៃការទទួលបញ្ជាជួញដូរមូលបត្រ*

- ➢ ការផ្គូរផ្គងលើកទី៥ នៅម៉ោង ១១:០០ ព្រឹក
- ➢ ការផ្គូរផ្គងលើកទី៦ នៅម៉ោង ១១:៣០ ព្រឹក

រូបភាពទី ៤.១: ពេលវេលាជួញដូរនៅផ្សារមូលបត្រកម្ពុជា

| វគ្គជួញដូរ | ម៉ោងបិទ/បើកវគ្គ | ចំនួនជួញដូរ | ម៉ោងជួញដូរ | វិធីសាស្ត្រជួញដូរ |
|---|---|---|---|---|
| វគ្គបើក | ០៨:០០ - ០៩:០០ ព្រឹក | ០១ ដង | ០៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គជួញដូរនិរន្តន៍ | ០៩:០០ - ១១:០០ ព្រឹក | មិនកំណត់ | ០៩:០០ - ១១:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃច្រើន (មានករណីលើកលែង) |
| វគ្គបិទ | ១១:០០ - ១១:៣០ ព្រឹក | ០១ ដង | ១១:៣០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |

- ចំពោះរូបិយប័ណ្ណបរទេសត្រូវប្តូរទៅជារូបិយប័ណ្ណជាតិ។

### ៤.១.២.២ ឯកតាបញ្ជា ឯកតាគម្លាតថ្លៃ

- ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជាគឺ ០១ (មួយ) ឯកតាមូលបត្រ។
- ឯកតាគម្លាតថ្លៃ សម្រាប់ថ្លៃនៃមូលបត្រនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖[22]

តារាងទី ៤.១: ឯកតាគម្លាតថ្លៃ

| ថ្លៃ | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាខុស | ឧទាហរណ៍ថ្លៃបញ្ជាត្រូវ |
|---|---|---|---|
| ]0-4,000[ | 10 | 2,555; 3,012 | 2,550; 3,010 |
| [4,000-20,000[ | 20 | 4,210; 19,525 | 4,200; 19,520 |
| [20,000-40,000[ | 50 | 20,110; 35,530 | 20,100; 35,550 |
| [40,000-100,000[ | 100 | 50,720; 90,450 | 50,700; 90,400 |
| [100,000-200,000[ | 200 | 150,500; 125,300 | 150,400; 125,400 |
| [200,000-400,000[ | 500 | 300,100; 350,200 | 300,000; 350,500 |
| [400,000-[ | 1,000 | 620,500; 851,100 | 621,000; 852,000 |

[22] សាស្ត្រាចារ្យ សៀវ សុស៊ីខា (២០១៨), *តួនាទីរបស់ផ.ម.ក. និងកិច្ចដំណើរការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា។*

### ៤.១.២.៣ ដែនកំណត់នៃការប្រែប្រួលថ្លៃមូលបត្រ

ដែនកំណត់នៃការប្រែប្រួលនៃថ្លៃមូលបត្រ សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់លើកដំបូង (ថ្លៃ ដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក.) នៅលើទីផ្សារបន្ទាប់គឺចន្លោះពី ៩០% ទៅ ១៥០% មានន័យថាវាប្រែប្រួលពី ១០% ទៅ ៥០% នៃថ្លៃមូល- ដ្ឋាន។ ចំណែកដែនកំណត់បម្រែបម្រួលប្រចាំថ្ងៃគឺ អនុញ្ញាតឲ្យប្រែប្រួលពី ៥% ទៅ ៥% នៃថ្លៃមូល-ដ្ឋាន។ វិនិយោគិនអាចដាក់បញ្ជាបានតែក្នុងចន្លោះនេះទេ បើដាក់ខុសពីបម្រែបម្រួលនេះនឹងមិនអាចបញ្ជាបានទេ។

### ៤.១.២.៤ គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរទាំងអស់ ត្រូវបានអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ (Single Price Auction)។

អាទិភាពនៃការបញ្ជាទិញ និងបញ្ជាលក់៖

**ក. ករណីតាមគោលការណ៍**

**១. អាទិភាពដោយគិតលើថ្លៃ (Price Priority)**

- បញ្ជាលក់ ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។
- បញ្ជាទិញ ដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

**២. អាទិភាពដោយគិតលើរយៈពេល (Time Priority)**

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

តារាងទី ៤.២: គោលការណ៍ដេញថ្លៃ

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | : | |
| | ៦,៥២០ | ៥០០[១] |
| | ៦,៥០០ | ១០០[២] ២០០[៣] |
| | ៦,៤៨០ | |
| | ៦,៤៦០ | |
| ៣០០[៣] ២០០[២] | ៦,៤២០ | |
| (ថ្លៃទាបបំផុត) ៤៥០[១] | ៦,៤០០ | |

ដូចដែលបានបង្ហាញក្នុងតារាងខាងលើ បញ្ជាទិញ (១) និងបញ្ជាលក់ (១) ត្រូវបានអនុវត្តស្របតាមអាទិភាពនៃថ្លៃ។ ក្នុងចំណោមបញ្ជាដែលមានថ្លៃស្មើគ្នា បញ្ជា (២) ដែលទទួលបានមុនមានអាទិភាពជាងបញ្ជា (៣)។

**ខ. ករណីនៃការបញ្ជាព្រមពេលគ្នា (Simultaneous Order)**

- ការបញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើការបញ្ជាសម្រាប់គណនីសមាជិក។
- ការបញ្ជាដែលមានបរិមាណច្រើនជាង មានអាទិភាពលើការបញ្ជាដែលមានបរិមាណតិចជាង ចំពោះការបញ្ជានៅពេលដូចគ្នា និងថ្លៃដូចគ្នា។ ក្នុងករណីការបញ្ជាមានបរិមាណស្មើគ្នាការបញ្ជាដែល ផ.ម.ក. ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។
- ការបែងចែកបរិមាណមូលបត្រ សម្រាប់ការបញ្ជាព្រមពេលគ្នា ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាពដូចតទៅ៖

១. ១០០ ដងនៃឯកតាជួញដូរ

២. ៥០០ ដងនៃឯកតាជួញដូរ

៣. ១០០០ ដងនៃឯកតាជួញដូរ

៤. ៥០% នៃបរិមាណដែលនៅសល់។ បើសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

៥. បរិមាណដែលនៅសល់ទាំងអស់ត្រូវផ្តល់ឲ្យតាមអាទិភាព។

ឧទាហរណ៍៖

តារាងទី ៤.៣: ការដាក់បញ្ជាព្រមពេលគ្នា

| Ask | | | | Price | | | Bid | |
|---|---|---|---|---|---|---|---|---|
| 4,000 | 1,500 | 600 | (6,100) | 73,500 | 1,000[1] | 200[2] | 10,000[3] | 5,000[4] |
| | 1,700 | 1,500 | (3,200) | 71,500 | 500 | 700 | | |
| | 1,300 | 1,000 | (2,300) | 70,000 | 400 | | | |
| | | 800 | (800) | 68,250 | | | | |
| | | 700 | (700) | 66,500 | | | | |
| | | | 13,100 | **Total** | 16,200 | | | |

❖ **កំណត់សម្គាល់**

1,000[1] : ការបញ្ជាទិញចំនួន ១,០០០ នៅលើកទី១

200[2] : ការបញ្ជាទិញចំនួន ២០០ នៅលើកទី២

10,000[3] : ការបញ្ជាទិញចំនួន ១០,០០០ នៅលើកទី៣

5,000[4] : ការបញ្ជាទិញចំនួន ៥,០០០ នៅលើកទី ៤

តារាងទី ៤.៤: ការបែងចែកបរិមាណមូលបត្រ

| | 1st (100) | 2nd (500) | 3rd (1,000) | 4th (1/2) | 5th (rest) | Traded |
|---|---|---|---|---|---|---|
| Order 3 (10,000) | 100 | 500 | 1,000 | 4,200 | 2,800 | 8,600 |
| Order 4 (5,000) | 100 | 500 | 1,000 | 1,700 | 0 | 3,300 |
| Order 1 (1,000) | 100 | 500 | 4,00 | 0 | 0 | 1,000 |
| Order 2 (200) | 100 | 100 | 0 | 0 | 0 | 200 |
| **Total** | **400** | **1,600** | **2,400** | **5,900** | **2,800** | **13,100** |

#### ៤.១.២.៥ ថ្លៃពិសេស

ថ្លៃពិសេស គឺជាសំណើលក់ល្អបំផុត (ទាបជាងថ្លៃមូលដ្ឋាន) ឬ សំណើទិញល្អបំផុត (ខ្ពស់ជាងថ្លៃមូលដ្ឋាន) ក្នុងករណីមិនបានអនុវត្តការជួញដូរហូតដល់ពេលបិទទីផ្សារ[23]។

តារាងទី ៤.៥: ថ្លៃពិសេស

| លក់ | ថ្លៃ | ទិញ |
|---|---|---|
| 5,000 | 6,300 | |
| | 6,280 | |
| 2,500 | 6,260 | ថ្លៃមូលដ្ឋាន |
| 1,000 | 6,240 | ថ្លៃពិសេស និងថ្លៃបិទទីផ្សារ |
| | 6,200 | 3,000 |
| | 6,160 | |

[23] សៀវ សុស៊ីខា (២០១៨), *តួនាទីរបស់ជ.ម.ក. និង កិច្ចដំណើរការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា*

## ៤.២ ដំណើរការការជួញដូរមូលបត្រលើទីផ្សារបន្ទាប់

ដំណើរការជួញដូរមូលបត្រនេះ ស្ថិតនៅក្រោមវិធានប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជានៅពេលដែលមូលបត្របានចុះបញ្ជីរួចនៅលើទីផ្សារមូលបត្រ។

### ៤.២.១ ដំណើរការអនុវត្តការជួញដូរមូលបត្រ

បន្ទាប់ពីវិនិយោគិនបានទទួលបានលេខអត្តសញ្ញាណប័ណ្ណវិនិយោគិន បើកគណនីជួញដូរ និងធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្ររួច វិនិយោគិនអាចចាប់ផ្តើមធ្វើការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។




T+0 T+1 T+2, 8:30 នាទី

❖ **ថ្ងៃជួញដូរ (T0)**

មុននឹងធ្វើការជួញដូរ វិនិយោគិនត្រូវបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូរ របស់ក្រុមហ៊ុនមូលបត្រឲ្យបានមុនម៉ោងជួញដូរ។ ម៉ោងជួញដូរនៅ ផ.ម.ក. ត្រូវបានបែងចែកជាពីរវគ្គ (Trading Session) ដែលវគ្គទីមួយចាប់ផ្តើមពីម៉ោង ៨:០០ ដល់ម៉ោង ៩:០០ ព្រឹក និងវគ្គទីពីរ ចាប់ផ្តើមពីម៉ោង ៩:០០ ដល់ម៉ោង ១១:៣០ ព្រឹក។

ការទទួលបញ្ជាទិញ ឬលក់មូលបត្រគឺចាប់ម៉ោង ៨:០០ ដល់ម៉ោង ១១:៣០ ព្រឹក ប៉ុន្តែការអនុវត្តជួញដូរ គឺធ្វើឡើងចំនួនពីរដង គឺនៅម៉ោង ៩:០០ ព្រឹកម្តង និងម៉ោង ១១:០០ នាទីព្រឹកម្តងទៀត។ ក្រោយពីការជួញដូរត្រូវបានបញ្ចប់នៅម៉ោង ១១:៣០ នាទីព្រឹកនៃថ្ងៃជួញដូរ (T0) រហូតដល់មុនម៉ោង ១២:០០ នាទីថ្ងៃត្រង់ នៃថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+១) គឺជាកំឡុងពេលសម្រាប់ការកែបញ្ជាទិញ ឬ លក់មូលបត្រ។

❖ **មួយថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+១)**

ពីម៉ោង ១២:១៥ នាទីថ្ងៃត្រង់ ប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់ (ផ.ម.ក.) ចាប់ផ្តើមធ្វើការផាត់ទាត់សាច់ប្រាក់ និងមូលបត្រ ដើម្បីស្វែងរកលទ្ធផលនៃចំនួនសាច់ប្រាក់ និងចំនួនមូលបត្រសរុបដែលវិនិយោគិនម្នាក់ៗត្រូវទទួលបាន។

ពីម៉ោង ១:៣០ ដល់ម៉ោង ២:៣០ នាទីថ្ងៃ ឬ មុនម៉ោង ២:៣០ នាទី ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ ចេញសេចក្តីណែនាំសម្រាប់ធ្វើការទូទាត់ (Settlement Instruction) ទៅកាន់

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) និងក្រុមហ៊ុនមូលបត្រ (SF)។ ការចេញសេចក្តីណែនាំនេះ គឺធ្វើឡើងដោយ ស្វ័យប្រវត្តិពីប្រព័ន្ធបច្ចេកវិទ្យារបស់ផ.ម.ក.។

❖ **ពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+២)**

មុនម៉ោង ៨:៣០ នាទីព្រឹក ក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញ ផ្ទេរសាច់ប្រាក់ពីគណនីក្រុមហ៊ុនមូលបត្រចូលទៅក្នុងគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO Account)។

ម៉ោង ១០:៣០ នាទីព្រឹក សាច់ប្រាក់ត្រូវបានផ្ទេរពីគណនីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) ទៅគណនីក្រុមហ៊ុនមូលបត្រ (SF) ដែលជាអ្នកលក់។ ស្របពេលជាមួយគ្នា មូលបត្រត្រូវបានផ្ទេរពីគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់ ទៅគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញ តាមរយៈគណនីមូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO Account)។

រូបភាពទី ៤.២: នីតិវិធីនៃការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា



(១) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់ និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយនៅមុនថ្ងៃជួញដូរមួយថ្ងៃ។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យបញ្ជាទិញ ឬ លក់ ទៅកាន់ក្រុមហ៊ុនមូលបត្រ ជាលាយលក្ខណ៍អក្សរ ពាក្យសម្តី (ការថតសម្លេង) ឬ មធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ ផ.ម.ក. ប៉ុន្តែមុននឹងដាក់បញ្ជា ក្រុមហ៊ុនមូលបត្របានបង្កកទុករួចហើយនូវសាច់ប្រាក់ ឬ បរិមាណមូលបត្រយ៉ាងហោចណាស់ ១០០% នៃបញ្ជានីមួយៗ។

(៤) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃ ដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផល នៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅ (T+0)។

(៧) ក្នុងករណីមានកំហុលឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ នោះក្រុមហ៊ុនមូលបត្រត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់ នៃថ្ងៃ T+១។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី ៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬ បញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង ក្រុមហ៊ុនមូលបត្រប្រើប្រាស់សាច់ប្រាក់ ឬ មូលត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ ដោយសុំ ឬ មិនបាច់សុំការអនុញ្ញាតពីអតិថិជនឡើយ។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ ផ.ម.ក.។

### ៤.២.២ យន្តការនៃការផាត់ទាត់ និងទូទាត់

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទូទាត់សាច់ប្រាក់ និងទូទាត់មូលបត្រនៅក្នុងដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ សមាជិក (សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. ដោយមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្ររបស់ ផ.ម.ក.) នៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ តម្រូវឲ្យបើកគណនី ០២ (ពីរ) ប្រភេទ គឺបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់ និងគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ។

### ៤.២.២.១ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់

មុននឹងចាប់ផ្ដើម ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អាចដំណើរការទៅបាន គ្រប់សមាជិក និងអ្នកពាក់ព័ន្ធនឹងការទូទាត់សាច់ប្រាក់ ចាំបាច់ត្រូវបើកគណនីទូទាត់សាច់ប្រាក់ ក្នុងគោលបំណងបំពេញកាតព្វកិច្ចក្នុងការទូទាត់សាច់ប្រាក់ ពេលធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

សមាជិកទាំងអស់តម្រូវឲ្យបើកគណនីសាច់ប្រាក់ ៣ សំខាន់ៗគឺ៖

- គណនីទូទាត់សាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ (Cash Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។ បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬ មានការផ្លាស់ប្ដូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនីទូទាត់ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ យ៉ាងហោចណាស់ ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្ដើមការជួញដូរ[24]។
- គណនីទូទាត់សាច់ប្រាក់ក្នុងនាមអតិថិជន (Client Money Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់នៅក្នុងប្រតិបត្តិការជួញដូរមូលបត្រ។ អតិថិជនអាចធ្វើការទូទាត់សាច់ប្រាក់ជាប្រាក់រៀល ឬ ដុល្លារអាមេរិចបាន ដែលនេះជាកត្តាមួយដែលបង្កភាពងាយស្រួលដល់អតិថិជន[25]។
- គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (Cash Settlement Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ជាប្រាក់រៀល ដើម្បីអនុញ្ញាតឲ្យប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់ទៅឲ្យសមាជិករបស់ខ្លួននៅកាលបរិច្ឆេទទូទាត់ជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិកទៅគណនីទូទាត់សាច់ប្រាក់ របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។

[24] ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១គ.ម.ក./ ប្រ.ក., ២៧ មិថុនា ២០១១, ប្រការ ៧

[25] គោលការណ៍ណែនាំស្ដីពី នីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ, លេខ ០០៣/១២គ.ម.ក.ស.ជ.ណ., ១៤ កុម្ភៈ ២០១៤។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

ចំពោះគណនីទូទាត់សាច់ប្រាក់ដែលបានបើករួច គឺអាចបិទបានក្នុងករណីដូចខាងក្រោម៖

១. សមាជិកបើកគណនីទូទាត់សាច់ប្រាក់ ដោយមិនបានធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់រវាងគ្នា និងគ្នាទាល់តែសោះអស់រយៈពេល ០២ ឆ្នាំ ដូចនេះ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) មានសិទ្ធិក្នុងការបិទគណនីទូទាត់សាច់ប្រាក់មួយនោះ។

២. សមាជិកស្នើសុំបិទគណនីទូទាត់សាច់ប្រាក់ដោយខ្លួនឯង។

**៤.២.២.២ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ**

ចំពោះប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ ការបើកគណនីទូទាត់សាច់ប្រាក់តែមួយដើម្បីបំពេញការទូទាត់ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដូច្នេះសមាជិក និងអ្នកពាក់ព័ន្ធនឹងការទូទាត់មូលបត្រចាំបាច់ ត្រូវបើកគណនីមួយប្រភេទទៀតគឺគណនីមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ ក្នុងប្រតិបត្តិការជួញដូរ។

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ។

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីទូទាត់មូលបត្រតំណាងឲ្យអតិថិជន នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដោយដាក់ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ និងមូលបត្រត្រូវចុះបញ្ជិក្រោមឈ្មោះរបស់កម្មសិទ្ធិករមូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រនិងធានាដល់ការទូទាត់មូលបត្រដែលជាសមាជិក។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីមូលបត្ររបស់សមាជិកទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។

ក្នុងករណីបិទគណនីមូលបត្រ ក្រុមហ៊ុនមូលបត្រត្រូវគោរពតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រដូចខាងក្រោម៖

១. ធ្វើការស្នើសុំបិទគណនីទូទាត់មូលបត្រដោយសមាជិកផ្ទាល់។

២. បន្ទាប់ពីសមាជិកបើកគណនីទូទាត់មូលបត្ររួច មិនមានប្រតិបត្តិការទូទាត់មូល-បត្រ ឬ ការផ្ទេរមូលបត្ររវាងគណនី និងគណនី ដូច្នេះប្រតិបត្តិកររក្សាទុកមូលបត្រមានសិទ្ធិក្នុងការបិទគណនីទូទាត់មូលបត្រនោះ។

**៤.២.២.៣ ដំណើរការផាត់ទាត់**

នៅពេលព័ត៌មានជួញដូរត្រូវបានបញ្ជាក់ដោយអតិថិជន និងបានផ្ទៀងផ្ទាត់ដោយសមាជិកទាំងអស់ដែលតំណាងឲ្យអតិថិជនរួចហើយ ក្រុមហ៊ុនមូលបត្រត្រូវតាំងនាមឲ្យអតិថិជន ក្នុងការទូទាត់សាច់ប្រាក់សម្រាប់មូលបត្រដែលបានទិញ ឬ បញ្ជូនមូលបត្រដែលបានលក់ទៅកាន់ភាគីម្ខាងទៀតដែលជាសមាជិក និងជាអន្តរការីរបស់អ្នកលក់មូលបត្រ ឬ អ្នកទទួលមូលបត្រដោយប្រើប្រាស់សាច់ប្រាក់ ឬ មូលបត្រ ដែលបានបង្កកទុករួចហើយ ក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ដោយធ្វើការបន្សុទ្ធ ឬ កាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិកនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវជូនព័ត៌មានដូចខាងក្រោមដល់សមាជិកនៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់៖

១. កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់

២. បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន។

៣. ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន។

- **វិធីសាស្ត្រនៃការផាត់ទាត់**

វិធីសាស្ត្រក្នុងការគណនាបរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវផាត់ទាត់មានដូចខាងក្រោម៖

១. ចំពោះមូលបត្រ៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិកដែលពាក់ព័ន្ធ។

២. ចំពោះសាច់ប្រាក់៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុបសម្រាប់សមាជិកនីមួយៗដែលពាក់ព័ន្ធ។

### ៤.២.២.៤ ដំណើរការទូទាត់

ការទូទាត់ គឺជាការបញ្ចប់ប្រតិបត្តិការដែលអ្នកលក់ផ្ទេរមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ចំណែកអ្នកទិញបានផ្ទេរសាច់ប្រាក់ទៅអ្នកលក់វិញ[26]។

នីតិវិធីនៃការផាត់ទាត់ និងទូទាត់មូលបត្រមានដំណើរការដូចខាងក្រោម៖

១. ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានពីការជួញដូរដែលបានបន្ស៊ីរួចរាល់ (Confirmed Trading) ទៅប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ បន្ទាប់មក ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការបន្សុទ្ធទាំងសាច់ប្រាក់ និងមូលបត្រទៅតាមព័ត៌មានដែលទទួលបាន។

២. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្របញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់ និងទូទាត់បរិមាណសាច់ប្រាក់ និងបរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវការធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន ទៅកាន់ក្រុមហ៊ុនមូលបត្រ (SFs) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) និងប្រតិបត្តិកររក្សាទុកមូលបត្រ (CSD)។

៣. បន្ទាប់មកទៀត ក្រុមហ៊ុនមូលបត្រត្រូវដាក់បញ្ជាទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីធ្វើការទូទាត់សាច់ប្រាក់ ទៅឲ្យសមាជិកដែលត្រូវទទួលបានសាច់ប្រាក់ ឬសមាជិកដែលបានលក់មូលបត្រ។

៤. ក្រុមហ៊ុនមូលបត្រត្រូវដាក់បញ្ជាទៅកាន់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធ្វើការផាត់ទាត់មូលបត្រ ទៅកាន់សមាជិកដែលត្រូវទទួលការមូលបត្រ ក្នុងនាមខ្លួនផ្ទាល់ ឬ តាំងនាមឲ្យអតិថិ-ជន[27]។

ការផាត់ទាត់ និងទូទាត់សម្រាប់ប្រតិបត្តិការជួញដូរនីមួយៗ៖

១. ករណីមូលបត្រ៖ ផាត់ទាត់ដោយ ផ.ម.ក. និងទូទាត់ដោយ ផ.ម.ក.។

២. ករណីសាច់ប្រាក់៖ ផាត់ទាត់ដោយ ផ.ម.ក. និងទូទាត់ដោយភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។[28]

#### ក. ការទូទាត់សាច់ប្រាក់

ការទូទាត់សាច់ប្រាក់ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការជួញដូរមូលបត្រកម្មសិទ្ធិ។ ដូចនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និង

[26] ផ្សារមូលបត្រកម្ពុជា (២០១៨), ប្រតិបត្តិការរបស់ផ.ម.ក., *តើអ្វីជាការទូទាត់?*
[27] គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *យន្តការនៃការផាត់ទាត់និងទូទាត់ សម្រាប់ផ្សារមូលបត្រនៅប្រទេសកម្ពុជា*
[28] សៀវ សុស៊ីខា (២០១៨), *ការផាត់ទាត់ និងទូទាត់មូលបត្រ ការរក្សាទុកមូលបត្រនៅផ្សារមូលបត្រកម្ពុជា*

បំបាត់នូវកំហុសឆ្គង ដែលអាចកើតឡើងជាយថាហេតុ នៅកំឡុងពេលប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ ផ្សារមូលបត្រកម្ពុជាបានបែងចែកការទូទាត់សាច់ប្រាក់ជា ០២ របៀបគឺ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ និងការទូទាត់សាច់ប្រាក់ជាអន្តរធនាគារ[29]។

❖ **ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ**

មុនដល់កាលបរិច្ឆេទទូទាត់ (T+២) ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ (CSO) ចាំបាច់ត្រូវបញ្ជូនព័ត៌មាននៃការបន្សុទ្ធសាច់ប្រាក់ និងមូលបត្រដែលត្រូវទូទាត់ទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។ បន្ទាប់មក នៅមុនម៉ោង ៨:៣០ នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+២) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់អតិថិជន (CMA) ក្នុងនាមជាអ្នកទិញទៅកាន់គណនីទូទាត់សាច់ប្រាក់របស់អតិថិជនក្នុងនាមជាអ្នកទិញដូចគ្នា ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ។ បន្ទាប់មកត្រូវផ្ទេរសាច់ប្រាក់ដែលត្រូវទូទាត់ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូល-បត្រ (ជ.ម.ក.) យ៉ាងយូរនៅត្រឹមម៉ោង ៨:៣០ នាទីព្រឹក។ រួចមក ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ (ជ.ម.ក.) ត្រូវបង្វែរសាច់ប្រាក់បន្ត ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជន ក្នុងនាមជាអ្នកលក់ដែលបានបើកគណនី ក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ យ៉ាងយូរត្រឹមម៉ោង ១០:៣០ នាទីព្រឹក។ ចប់ម៉ោង ១០:៣០ នាទីនៃកាលបរិច្ឆេទទូទាត់ (T+២) ក្រុមហ៊ុនមូលបត្រត្រូវផ្ទេរសាច់ប្រាក់ចូលក្នុងគណនីអតិថិជនដែលជាអ្នកលក់។

ក្រោយពីចប់សព្វគ្រប់ហើយ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងដល់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រអំពីការទូទាត់សាច់ប្រាក់ដែលបានអនុវត្តរួច។

❖ **ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ**

នៅក្នុងការទូទាត់សាច់ប្រាក់តាមរយៈធនាគារ ពីរផ្សេងគ្នា ត្រូវបានអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់ការប្រឹក្សាដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA1) ខាងអ្នកទិញ និងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA2) ខាងអ្នកលក់ អំពីទម្រង់នៃការផ្ទេរសាច់ប្រាក់រវាងគ្នានឹងគ្នា។ បន្ទាប់មកមុនម៉ោង ៨:

[29] ហ៊ាង បុទម្យ និងហង់ ពិសី, "*យន្តការជាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ*", (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៤, ៤៧-៤៨)។

៣០ នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+២) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ (CSA1) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីអតិថិជនរបស់អ្នកទិញ ទៅកាន់គណនីទូទាត់សាច់ប្រាក់ក្នុងនាមជាអ្នកទិញ ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (CSO) ដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ (CSA1) យ៉ាងយូរមុនម៉ោង ៨:៣០ នាទីព្រឹក។ ក្រោយមកទៀត (CSA1) ត្រូវផ្ទេរសាច់ប្រាក់ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់ (CSA2) ឆ្លងតាមរយៈសភាផាត់ទាត់នៃធនាគារជាតិនៃកម្ពុជា (NBC)។ នៅថ្ងៃដដែល ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជន ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់ (CSA2) យ៉ាងយូរត្រឹមម៉ោង ១០:៣០ នាទីព្រឹក។ រួចមក ក្រុមហ៊ុនមូលបត្រខាងអ្នកលក់ ត្រូវផ្ទេរសាច់ប្រាក់បន្តទៅកាន់គណនីអតិថិជនរបស់អ្នកលក់។

ចុងបញ្ចប់ ក្រុមហ៊ុនមូលបត្រទាំងសងខាងត្រូវត្រួតពិនិត្យពីសមតុល្យសាច់ប្រាក់ក្នុងគណនីអតិថិជន ថាតើក្នុងគណនីអតិថិជនខាងអ្នកលក់បានទទួលសាច់ប្រាក់ដូចតាមការទូទាត់ដែរ ឬទេ។

**ខ. ការទូទាត់មូលបត្រ**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រ អំពីការទូទាត់សាច់ប្រាក់ត្រូវបានបំពេញរួចរាល់ ចប់សព្វគ្រប់អស់ហើយ។ បន្ទាប់មក ប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងឲ្យអតិថិជន (អ្នកលក់) ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្ររបស់ CSO ដែលបានបើកនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធ្វើការផាត់ទាត់មូលបត្រ នៅពេលមានប្រតិបត្តិការជួញដូរមូលបត្រកើតមានឡើង។ ក្រោយមកទៀត ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ()CSO ត្រូវធ្វើការផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងឲ្យអតិថិជន (អ្នកទិញ)។

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវជូនដំណឹងទៅកាន់តួអង្គដែលពាក់ព័ន្ធក្នុងការផាត់ទាត់មូលបត្រ ដូចជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ និងក្រុមហ៊ុនមូលបត្រទាំងសងខាង។

### ៤.២.២.៥ កម្រៃសេវាផាត់ទាត់និងទូទាត់

សមាជិកត្រូវបង់កម្រៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រតាមអត្រា និងពេលវេលាដូចខាងក្រោម៖

១. កម្រៃសេវាសម្រាប់សេវាផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់ក្បៀសមកត្រឹមមួយខ្ទង់) តាមអត្រា ២.៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ)។

២. អ្នកបង់កម្រៃសេវាគឺ ក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

៣. ពេលវេលានៃការបង់កម្រៃសេវាគឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់[30]។

### ៤.២.៣ យន្តការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេររវាងគណនី (Book Entry) ដោយគ្មានការផ្ទេរមូលបត្ររូប-វន្ត។ ដូចនេះហានិភ័យកើតចំពោះការបាត់ និង ការលួចមូលបត្រត្រូវបានចៀសវាងទាំងស្រុង។ សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ ផ.ម.ក. មិនចាំបាច់ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួម

[30] ប្រកាសស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, លេខ ០០១/១៤គ.ម.ក./ប្រ.ក., ២២ មករា ២០១៤, ប្រការ១៨ថ្មី។

មានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger (ledger system) របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ :

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ[31]។

## ៤.៣ ទិន្នន័យសំខាន់ៗទាក់ទងនឹងការជួញដូរមូលបត្រនៅកម្ពុជា

ក្រាបខាងក្រោម (រូបភាពទី៤.៣) បានបង្ហាញឲ្យឃើញថា ការជួញដូរមូលបត្រសរុបចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៦ គឺភាគច្រើនបានពីវិនិយោគិនបរទេស[32]។

[31] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ, លេខ ០០២/១១គ.ម.ក./ប្រ.ក., ០៣ ឧសភា ២០១១, ប្រការ៥

[32] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, "*ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានិងទីផ្សារមូលធន*", (បទបង្ហាញក្នុងកិច្ចប្រជុំក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ២៧ កក្កដា ២០១៧)

រូបភាពទី ៤.៣: ការជួញដូរមូលបត្រសរុបរបស់វិនិយោគិនក្នុងស្រុក និងបរទេស




- ក្នុងឆ្នាំ ២០១២ ការជួញដូរសរុបរបស់វិនិយោគិនក្នុងស្រុក បើគិតជាភាគរយមាន ៤៣% រីឯវិនិយោគិនបរទេសមានដល់ទៅ ៥៧%។
- ក្នុងឆ្នាំ ២០១៣ ការជួញដូរសរុបរបស់វិនិយោគិនក្នុងស្រុក បើគិតជាភាគរយមាន ៣២% រីឯវិនិយោគិនបរទេសមានដល់ទៅ ៦៨%។
- ក្នុងឆ្នាំ ២០១៤ ការជួញដូរសរុបរបស់វិនិយោគិនក្នុងស្រុក បើគិតជាភាគរយមាន ៤៧% រីឯវិនិយោគិនបរទេសមានដល់ទៅ ៥៣%។
- ក្នុងឆ្នាំ ២០១៥ ការជួញដូរសរុបរបស់វិនិយោគិនក្នុងស្រុក បើគិតជាភាគរយមាន ២៤% រីឯវិនិយោគិនបរទេសមានដល់ទៅ ៦៧%។
- ក្នុងឆ្នាំ ២០១៦ ការជួញដូរសរុបរបស់វិនិយោគិនក្នុងស្រុក បើគិតជាភាគរយមាន ៣៨% រីឯវិនិយោគិនបរទេសមានដល់ទៅ ៦២%។

យោងតាមក្រាបខាងក្រោម (រូបភាពទី៤.៤) យើងឃើញថាការជួញដូរសរុបនៃនីតិបុគ្គលមានកម្រិតខ្ពស់ជាងរូបវន្តបុគ្គល មានន័យថាវិនិយោគិនដែលជាបុគ្គលម្នាក់ៗ មានលំហូរសាច់ប្រាក់ទៅក្នុងទីផ្សារមូលបត្រកម្ពុជាច្រើន។

រូបភាពទី ៤.៤: ការជួញដូរមូលបត្រសរុបនៃនីតិបុគ្គល និងរូបវន្តបុគ្គល




- ក្នុងឆ្នាំ ២០១២ ការជួញដូរសរុបរបស់វិនិយោគិននីតបុគ្គល បើគិតជាភាគរយមាន ២២% រីឯ វិនិយោគិនរូបវន្តបុគ្គលមានដល់ទៅ ៧៨%។
- ក្នុងឆ្នាំ ២០១៣ ការជួញដូរសរុបរបស់វិនិយោគិននីតបុគ្គល បើគិតជាភាគរយមាន ១៥% រីឯ វិនិយោគិនរូបវន្តបុគ្គលមានដល់ទៅ ៨៥%។
- ក្នុងឆ្នាំ ២០១៤ ការជួញដូរសរុបរបស់វិនិយោគិននីតបុគ្គល បើគិតជាភាគរយមាន ១៨% រីឯ វិនិយោគិនរូបវន្តបុគ្គលមានដល់ទៅ ៨២%។
- ក្នុងឆ្នាំ ២០១៥ ការជួញដូរសរុបរបស់វិនិយោគិននីតបុគ្គល បើគិតជាភាគរយមាន ២៤% រីឯ វិនិយោគិនរូបវន្តបុគ្គលមានដល់ទៅ ៧៨%។
- ក្នុងឆ្នាំ ២០១៦ ការជួញដូរសរុបរបស់វិនិយោគិននីតបុគ្គល បើគិតជាភាគរយមាន ១៨% រីឯ វិនិយោគិនរូបវន្តបុគ្គលមានដល់ទៅ ៨២%។

យោងតាមក្រាបខាងក្រោមនេះ (រូបភាពទី៤.៥) បរិមាណនិងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំឆ្នាំ ២០១២ មានចំនួនច្រើនជាងគេ ប្រៀបធៀបនឹងឆ្នាំបន្ទាប់មកទៀតដែលមានការធ្លាក់ចុះ។ ដោយឡែកនៅពាក់កណ្តាលឆ្នាំ ២០១៧ ក៏មានការកើនឡើងមកវិញគឺច្រើនជាងឆ្នាំ ២០១៣, ២០១៤ និង២០១៥។

រូបភាពទី ៤.៥: បរិមាណ និងតម្លៃនៃការជួញដូរមូលបត្រសរុបប្រចាំថ្ងៃគិតជាមធ្យម




- ក្នុងឆ្នាំ ២០១២ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ៥៧,០៨២ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១១៨,២៥២ដុល្លាអាមេរិច ។
- ក្នុងឆ្នាំ ២០១៣ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១០,១៨៥ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១៥,១៦២ដុល្លាអាមេរិច ។
- ក្នុងឆ្នាំ ២០១៤ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ៧,៧៤០ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១៣,១៥៩ដុល្លាអាមេរិច ។
- ក្នុងឆ្នាំ ២០១៥ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ៦,៣៧៥ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ៧,៨៣៧ដុល្លាអាមេរិច ។
- ក្នុងឆ្នាំ ២០១៦ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១០,៨៤៨ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១០,៣៩៨ដុល្លាអាមេរិច ។
- នៅពាក់កណ្តាលឆ្នាំ ២០១៧ បរិមាណជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១៥,៥៦៤ និងតម្លៃជួញដូរសរុបនៃការជួញដូរប្រចាំថ្ងៃគិតជាមធ្យមមាន ១៣,៧៧៩ ដុល្លាអាមេរិច ។

យោងតាមក្រាបខាងក្រោមនេះ (រូបភាពទី ៤.៦)ចំនួនគណនីវិនិយោគិនក្នុងឆ្នាំ ២០១៧ គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៧ មានគណនីវិនិយោគិនបរទេសចំនួន ២,៦៣៨ (គិតជាភាគរយមាន ៣១%) និងគណនីវិនិយោគិនក្នុងស្រុកមានចំនួន ៥,៨៧៣ (គិតជាភាគរយមាន ៦៩%)។

រូបភាពទី ៤.៦: ចំនួនគណនីជួញដូរមូលបត្រ




យោងតាមតារាងខាងក្រោម (តារាងទី ៤.៦) យើងឃើញថាគិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៧ វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនជាងគេគឺ វិនិយោគិនចិន ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ១៤.៥៩លានដុល្លាអាមេរិច គិតជាភាគរយមាន ៤៨.១៣%។

- វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនលំដាប់ទី ២ គឺវិនិយោគិនជប៉ុន ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ៥.២៥លានដុល្លាអាមេរិច គិតជាភាគរយមាន ១៧.៣៤%។
- វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនលំដាប់ទី ៣ គឺវិនិយោគិនតៃវ៉ាន់ ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ៣.១១លានដុល្លាអាមេរិច គិតជាភាគរយមាន ១០.២៧%។
- វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនលំដាប់ទី ៤ គឺវិនិយោគិនឆេននៃល អាយឡេន ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ២.២៥លានដុល្លាអាមេរិច គិតជាភាគរយមាន ៧.៤៣%។
- វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនលំដាប់ទី ៥ គឺវិនិយោគិនកូរ៉េ ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ១.២៦លានដុល្លាអាមេរិច គិតជាភាគរយមាន ៤.១៧%។
- វិនិយោគិនបរទេសដែលធ្វើការជួញដូរច្រើនលំដាប់ទី ៦ គឺវិនិយោគិនម៉ាឡេស៊ី ដែលមានតម្លៃនៃការជួញដូរសរុបដល់ទៅ ១.២៥លានដុល្លាអាមេរិច គិតជាភាគរយមាន ៤.១១%។

តារាងទី ៤.៦: វិនិយោគិនបរទេសសំខាន់ៗទាំង ៦ក្នុងផ្សារមូលបត្រកម្ពុជា
(គិតត្រឹមថ្ងៃទី ៣០ មិថុនា ២០១៧)

| No. | Nationality | Value (million USD) | Percentage |
|---|---|---|---|
| 1 | China | 14.59 | 48.13% |
| 2 | Japan | 5.25 | 17.34% |
| 3 | Taiwan | 3.11 | 10.27% |
| 4 | Channel Islands | 2.25 | 7.43% |
| 5 | Korea | 1.26 | 4.17% |
| 6 | Malaysia | 1.25 | 4.11% |

## ៤.៤ ចំណុចខ្លាំង និងចំណុចខ្សោយនៃការជួញដូរមូលបត្រនៅកម្ពុជា

ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើដំណើរការជួញដូរមូលបត្រនៅកម្ពុជារួចមក យើងអាចធ្វើការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបសទីផ្សារមូលបត្រកម្ពុជាបានដូចខាងក្រោម៖

### ៤.៤.១ ចំណុចខ្លាំង

- ដោយមានការចូលរួមភាគហ៊ុនពីក្រុមហ៊ុនមូលបត្រកូរ៉េ និងការបង្ហាត់បង្ហាញពីបុគ្គលិកមានជំនាញ ដែលជាហេតុធ្វើឲ្យការរៀបចំ និងប្រតិបត្តិការក្នុងទីផ្សារមានលក្ខណ:ច្បាស់លាស់ និងងាយស្រួលយល់។
- ការដាក់ឲ្យអនុវត្តនូវច្បាប់ បទបញ្ញត្តិ វិធានការ និងប្រកាសដែលទាក់ទងនឹងប្រតិបត្តិទីផ្សារ និងដំណើរការជួញដូរមានប្រសិទ្ធភាព
- ការដាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយ:គេហទំព័របានក្បោះក្បាយ ដែលជាហេតុងាយស្រួលដល់មហាជនក្នុងការទទួលយកព័ត៌មានបន្ថែម។
- ប្រព័ន្ធបច្ចេកវិទ្យាត្រឹមត្រូវសម្រាប់ដាក់អនុវត្តក្នុងយន្តការផាត់ទាត់ និងទូទាត់ ព្រមទាំងរក្សាទុកមូលបត្រ។
- ការរៀបចំឡើងនូវសិក្ខាសិលាអប់រំ និងវគ្គបំប៉នខ្លីៗដើម្បីបណ្តុះបណ្តាលវិជ្ជាជីវ:ទាក់ទងនឹងមូលបត្រ។

- ការបើកឲ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិស្សិត និងមហាជនក្នុងការអនុវត្តទិញលក់មូលបត្រនៅលើទីផ្សារ ក្នុងគោលបំណងបញ្ជ្រាបព័ត៌មានឲ្យកាន់តែទូលំទូលាយ។

### ៤.៤.២ ចំណុចខ្សោយ

- ជាក់ស្តែង ចំណេះដឹងទាក់ទងនឹងការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជារបស់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុកនៅមានកម្រិតនៅឡើយ។
- ក្រុមហ៊ុនចុះបញ្ជីក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចំនួនតិច ដែលជាហេតុធ្វើឲ្យមានជម្រើសតិចក្នុងការជ្រើសរើស។
- ចំនួននៃប្រតិបត្តិការជួញដូរមានកម្រិតទាបនៅឡើយ ដែលនាំឲ្យវិនិយោគិនខ្វះការទុកចិត្តលើក្រុមហ៊ុនមូលបត្រ និងដំណើរការទីផ្សារ។

# សេចក្តីសន្និដ្ឋាន និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការស្រាវជ្រាវទៅលើប្រធានបទ តាមរយៈការដកស្រង់ព័ត៌មានពាក់ព័ន្ធពីប្រព័ន្ធអ៊ីនធើណេត បណ្ណាល័យ និងឯកសារយោងពីសាស្ត្រាចារ្យកន្លងមក អាចឲ្យយើងសង្កេតឃើញថា ដំណើរការនៃការជួញដូរមូលបត្រនៅលើទីផ្សារបន្ទាប់ក្នុងប្រទេសកម្ពុជា ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះបើសិនជាវិនិយោគិនពុំមានការយល់ដឹងអំពី ការប្រព្រឹត្តទៅនៃការទិញលក់មូលបត្រនោះទេ វិនិយោគិននឹងមិនមានទឹកចិត្តក្នុងការវិនិយោគឡើយ ពីព្រោះពួកគេមិនមានការទុកចិត្តក្នុងការបណ្តាក់ទុនក្នុងវិស័យនេះ។ យើងឃើញថា បច្ចុប្បន្នទីផ្សារមូលបត្រមានបញ្ហាចោទជាច្រើនទាក់ទងនឹងការធ្លាក់ចុះនៃថ្លៃភាគហ៊ុន ចំនួនក្រុមហ៊ុនមូលបត្រនៅលើទីផ្សារ និងទំនុកចិត្តត្រូវបានលើកឡើងមកពិភាក្សាដើម្បីរកដំណោះស្រាយ។

ដើម្បីចូលរួមផ្តល់ជាដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ឲ្យអនុវត្តនូវច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលទាក់ទងនឹងវិស័យនេះ ក្នុងគោលបំណងធានាដល់ការប្រព្រឹត្តទៅដ៏ត្រឹមត្រូវរបស់ទីផ្សារទាំងមូល។ ស្របពេលជាមួយគ្នានេះដែរ យើងឃើញមានការដាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយៈគេហទំព័របានក្បោះក្បាយ ដែលជាហេតុងាយស្រួលដល់មហាជនក្នុងការទទួលយកព័ត៌មានបន្ថែម។ ចំពោះការផាត់ទាត់ និងទូទាត់ ព្រមទាំងរក្សាទុកមូលបត្រ ក៏ត្រូវបានធ្វើឡើងដោយប្រព័ន្ធបច្ចេកវិទ្យាត្រឹមត្រូវដែរ។ ក្រៅពីនេះ ការរៀបចំឡើងនូវសិក្ខាសិលាអប់រំ និងវគ្គបំប៉នខ្លីៗដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈទាក់ទងនឹងមូលបត្រ។ ការបើកឲ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិស្សិត និងមហាជនក្នុងការអនុវត្តទិញលក់មូលបត្រនៅលើទីផ្សារ ក្នុងគោលបំណងបញ្ជ្រាបព័ត៌មានឲ្យកាន់តែទូលំទូលាយ។

សរុបសេចក្តីមក ទីផ្សារមូលបត្រកម្ពុជាអាចចាត់ទុកបានជាកាតាលីករមួយដ៏សំខាន់ក្នុងការជំរុញនូវការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ឲ្យបានទូលំទូលាយជាងមុន និងរួមចំណែកដល់ការអភិវឌ្ឍសេចកិច្ចជាតិ។

# អនុសាសន៍

ដោយសារតែភាពវ័យក្មេងនៃវិស័យមូលបត្រនៅប្រទេសកម្ពុជា ប្រជាជនកម្ពុជាយើងមិនសូវមានចំណេះដឹងទូលំទូលាយលើដំណើរការនៃការជួញដូរមូលបត្រនៅឡើយទេ។ ដើម្បីជាជំនួយដល់ប្រសិទ្ធភាពនៃទីផ្សារមូលបត្រ គឺចាំបាច់ត្រូវមានការចូលរួមនិងសហការពីសំណាក់ស្ថាប័នឯក-ជន ស្ថាប័នសាធារណៈ និងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការផ្សព្វផ្សាយពីទូលំទូលាយជាងនេះ។ ដូច្នេះនាងខ្ញុំ សូមរួមចំណែកផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- គណៈកម្មការមូលបត្រកម្ពុជា គួររៀបរៀងសៀវភៅណែនាំខ្លីៗស្តីពីយន្តការ ឬ ដំណើរការនៃការជួញដូរមូលបត្រ ដោយធ្វើការសម្រាយពីច្បាប់បញ្ញត្តិ អនុក្រឹត្យ និងគោលការណ៍ណែនាំផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដើម្បីចែកដល់វិនិយោគិនក្រុមហ៊ុនមូលបត្រ ក៏ដូចជាប្រជាពលរដ្ឋ និងសិស្សនិស្សិតទូទៅ។ ការធ្វើដូចនេះ នឹងផ្តល់ភាពងាយស្រួលដល់វិនិយោគិន និង បងប្អូនប្រជាពលរដ្ឋក្នុងការស្វែងយល់ពីមូលបត្រ។
- ដើម្បីជំរុញនូវការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជី និងការវិនិយោគនៅលើទីផ្សារកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរណាបង្កើតឲ្យមានរង្វាន់លើកទឹកចិត្តសម្រាប់ក្រុមហ៊ុនចុះបញ្ជីដំបូង និងវិនិយោគិនដែលបានជួញដូរច្រើន។
- ក្រុមហ៊ុនមូលបត្រកម្ពុជា គួរតែសិក្សាស្វែងយល់បន្ថែមពីយុទ្ធសាស្ត្រនានាដែលបានអនុវត្តក្នុងវិស័យនេះពីប្រទេសជិតខាង។
- ក្រុមហ៊ុនមូលបត្រកម្ពុជា គួរលើកទឹកចិត្តឲ្យក្រុមហ៊ុនឯកជន និងសាធារណៈបោះផ្សាយមូលបត្របំណុល ដែលជាផ្នែកមួយនៃឧបករណ៍ហិរញ្ញវត្ថុ។
- បង្កើនចំនួនសិក្ខាសិលាជាសាធារណៈ និងការតាំងពិព័រណ៍ព័ត៌មានស្តីពីមូលបត្រ ដោយមានការចូលរួមពីអ្នកជំនាញពាក់ព័ន្ធនឹងការជួញដូរមូលបត្រលើផ្សារមូលបត្រកម្ពុជា។
- បន្តការបង្កើតឲ្យមានការប្រកួតប្រជែងទាក់ទងនឹងការជួញដូរមូលបត្រ ដើម្បីជាកត្តាទាក់ទាញចំណាប់អារម្មណ៍ពីមហាជន ឲ្យមានការចង់ដឹងលឺពីវិស័យមូលបត្រនៅកម្ពុជា។ ម្យ៉ាងទៀត កម្មវិធីប្រកួតប្រជែងគឺជាជំហានដំបូង និងជាជំហានមានប្រសិទ្ធិភាពមួយក្នុងការផ្សព្វផ្សាយព័ត៌មាន និងនីតិវិធីទាក់ទងនឹងការជួញដូរមូលបត្រ។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងវិស័យមូលបត្រ

- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨, ១៩ តុលា ២០០៧, មាត្រាទី ៣៨។
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ, លេខ ០០៥/១១
  គ.ម.ក./ប្រ.ក., ២៧ មិថុនា ២០១១, ប្រការ៧។
- ប្រកាសស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លេខ ០០១/១៤គ.ម.ក./ប្រ.ក., ២២ មករា ២០១៤, ប្រការ១៤ ថ្មី។
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ, លេខ ០០២/១១គ.ម.ក./ប្រ.ក., ០៣ ឧសភា ២០១១, ប្រការ៥
- គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ ០០១/គ.ម.ក./គ.ណ.ន., ៦ ខែកុម្ភៈ ឆ្នាំ ២០១២។
- គោលការណ៍ណែនាំស្តីពីយន្តការនៃការទទួលបញ្ជាជួញដូរមូលបត្រ, លេខ ១៥២គ.ម.ក./គ.ណ.ន., ១៧ មីនា ២០១៤។
- គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការទូទាត់សាច់ប្រាក់នៅក្នុងទីផ្សារមូលបត្រ, លេខ ០០៣/១២ គ.ម.ក.ស.ជ.ណ., ១៤ កុម្ភៈ ២០១៤។

### សៀវភៅ និងអត្ថបទសិក្សា


- គណៈកម្មការមូលបត្រកម្ពុជា. ២០១៤. *យន្តការនៃការផាត់ទាត់និងទូទាត់សម្រាប់ផ្សារមូល-បត្រនៅប្រទេសកម្ពុជា,* ភ្នំពេញ៖ គណៈកម្មការមូលបត្រកម្ពុជា។
- សួន ចំរើន. ២០០៩. "ធនាគារ និងហិរញ្ញវត្ថុ", មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សៀវ សុស៊ីខា. ២០១៧. "កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា", មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី ៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- សៀវ សុស៊ីខា. ២០១៨. "តួនាទីរបស់ផ.ម.ក. និងកិច្ចដំណើរការជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា," មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី ៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សៀវ សុស៊ីខា. ២០១៨. "ការជាត់ទាត់ និងទូទាត់មូលបត្រ ការរក្សាទុកមូលបត្រនៅផ្សារមូលបត្រកម្ពុជា", មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី ៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ឆេង សុភក្ត្រា និងឆេង ដាលីន. ២០១២. "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា", និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ហ៊ាង បុទម្យ និងហង់ ពិសី. ២០១៤. "យន្តការជាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ", និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។


**ឯកសារដកស្រង់ពីគេហទំព័រ**


- គណៈកម្មការមូលបត្រកម្ពុជា (២០១៧), *"ព្រឹត្តិបត្តិមូលបត្រ" ចេញផ្សាយលេខ ២ ខែមករា ឆ្នាំ ២០១៧,* ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/m78.php?pn=8 (ថតចម្លងថ្ងៃទី ២៥ឧសភា ២០១៨)
- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *គណៈកម្មការមូលបត្រកម្ពុជាគឺជាអ្វី?* ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/faq.php?pn=2 (ថតចម្លងថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៨)
- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រកម្ពុជា,* ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/faq.php?pn=2 (ថតចម្លងថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៨)
- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *អន្តរការីទីផ្សារ: ក្រុមហ៊ុនធានាទិញមូលបត្រ,* ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/m52.php?pn=6 (ថតចម្លងថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៨)
- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *អន្តរការីទីផ្សារ,* ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/m52.php?pn=6 (ថតចម្លងថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០១៨)

- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *ចក្ខុវិស័យ និងបេសកកម្ម*, ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/m11.php?pn=1 (ថតចម្លងថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០១៨)
- គណៈកម្មការមូលបត្រកម្ពុជា (២០១៨), *រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា*, ដកស្រង់ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1 (ថតចម្លងថ្ងៃទី៥ មិថុនា ឆ្នាំ ២០១៨)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០១៨), *ចក្ខុវិស័យ និងបេសកកម្ម*, ដកស្រង់ពីគេហទំព័រ: http://www.csx.com.kh/kh/about/mission.jsp?MNCD=1020 (ថតចម្លងថ្ងៃទី៧ មិថុនា ឆ្នាំ២០១៨)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (២០១៨), *រចនាសម្ព័ន្ធគ្រប់គ្រង*, ដកស្រង់ពីគេហទំព័រ: http://www.csx.com.kh/kh/about/org.jsp?MNCD=10302 (ថតចម្លងថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១៨)
- ផ្សារមូលបត្រកម្ពុជា (២០១៨), *ប្រតិបត្តិការរបស់ផ.ម.ក., នីតិវិធីមូលដ្ឋាននៃការជួញដូរ,* ដកស្រង់ពីគេហទំព័រ: http://www.csx.com,kh/operation/market/listPosts.do?MNCD=3020 (ថតចម្លងថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០១៨)
- ផ្សារមូលបត្រកម្ពុជា (២០១៨), *ប្រតិបត្តិការរបស់ផ.ម.ក., តើអ្វីជាការទូទាត់?* ដកស្រង់ពីគេហទំព័រ : http://www.csx.com.kh/operation/clearing/listPosts.do?MNCD=3030 (ថតចម្លងថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៨)
- Investopedia. (2018). *What is "Derivative"?* Retrieved on June 25 2018 from the link: https://www.investopedia.com/terms/d/derivative.asp
- Investopedia. (2018). *What is 'Underwriter'?* Retrieved on June 25 2018 from the link: https://www.investopedia.com/terms/u/underwriter.asp
- Trading Economics. (2018). *Cambodia GDP*. Retrieved on May 3 2017 from the link: https://tradingeconomics.com/cambodia/gdp